CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ សម្រាប់ខែធ្នូ ឆ្នាំ២០១៦ លក់តម្លៃ ១០០០រៀល លេខ ៩៨



រូបថតដោយ រិទ្ធី

## អំណរសប្បាយឬការរីករាយនៅតែជាខ្លឹមនៃបុណ្យព្រះយេស៊ូប្រសូត ឬបុណ្យគ្រីស្តស្ម៍ាសនៅកម្ពុជា

## សេចក្តីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " (Apologeticus, Chapter 50:Tertullian)។ បងប្អូន ជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ផ៍ត្រសិរី អ្នករៀបចំសំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្តល់ព័ត៌មានបន្ថែម អំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទ ឬសៀវភៅដែលគាត់សរសេរវត្ថុអនុស្សាវរីយរបស់គាត់ខ្លះ។ល។ សូមផ្តល់ឈ្មោះអ្នកដែលអាចផ្តល់សក្ខីភាពបានជូនមកឲ្យខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

Tel : 077 800 211 / 096 34 22 144 ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ Email: martyrscambodia@gmail.com



# រីករាយបុណ្យព្រះយេស៊ូប្រសូតឆ្នាំ២០១៦ !

*បងប្អូនជាទីស្រឡាញ់!*

ព្រះអម្ចាស់យេស៊ូបានប្រសូតមកជាង២០០០ឆ្នាំមកហើយ។ ព្រះអង្គប្រសូតបាននាំមកនូវអំណរសប្បាយ ដ៏រីករាយដល់មនុស្សទាំងអស់ក្នុងពិភពលោកទាំងមូល។

អ្នកនាំសារ សូមជូនពរបងប្អូនក្នុងឱកាសដ៏វិសេសវិសាលនេះ ឲ្យបានព្រះពរយ៉ាងពេញលក្ខណៈ ដែលមកពីព្រះជាម្ចាស់។ សូមព្រះអម្ចាស់យេស៊ូគ្រីស្ត ដែលបានកើតជាមនុស្សយ៉ាងពិតប្រាកដ ពីព្រះនាងព្រហ្មចារិនីម៉ារី ប្រទានកម្លាំង ស្មារតី សុភមង្គល សុខភាពល្អ អំណរសប្បាយគ្រប់ក្រុមគ្រួសារ។ សូមឲ្យពន្លឺនៃសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត នាំបងប្អូនឲ្យប្រែចិត្តគំនិត ឲ្យចេះសម្រុះសម្រួល លើកលែងទោសឲ្យគ្នា គោរពគ្នា សហការគ្នា និងបម្រើគ្នាទៅវិញទៅមក យកចិត្តទុកដាក់ ចំពោះអ្នកតូចតាច គ្មានទីពឹង កុមារកំព្រា ជនពិការ ព្រមទាំងបងប្អូនទាំងអស់ដែលងាយរងគ្រោះ។ សូមឲ្យពន្លឺនៃធម៌មេត្តារបស់ព្រះគ្រីស្តយេស៊ូ ជួយឲ្យចេះកសាង សន្តិភាព សេចក្តីសុខសាន្ត និងសុខដុមរមនាក្នុងគ្រួសារ សហគមន៍ និងក្នុងសង្គមកម្ពុជាទាំងមូល។

រីករាយបុណ្យព្រះយេស៊ូប្រសូត! សួស្តីឆ្នាំថ្មី ២០១៧!

សូមព្រះអង្គគង់នៅជាមួយបងប្អូនជានិច្ច។


CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh


ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខៈ ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# រដ្ឋមន្ត្រីក្រសួងអប់រំធ្វើទស្សនកិច្ចនៅសាលាមត្តេយ្យសិក្សាតាមគរុកោសល្យម៉ុងតេស្សូរីនៅខេត្តតាកែវ

សាលាមត្តេយ្យសន្តិតេរេសានៅជនបទដាច់ស្រយាល តែមានលក្ខណៈ ល្អប្រសើរទាំងបរិស្ថាន និងបច្ចេកទេស។ នេះជាប្រសាសន៍របស់ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា បណ្ឌិត ហង់ ជួនណារ៉ុន ក្នុងពេលបំពេញទស្សនកិច្ចផ្លូវការនៅសាលាមត្តេយ្យសន្តិតេរេសា នៃព្រះសហគមន៍កាតូលិក ក្នុងភូមិចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវកាលពីថ្ងៃទី២១ ធ្នូនេះ។

ឯកឧត្តមរដ្ឋមន្ត្រី បានធ្វើដំណើរទស្សនកិច្ចនេះ ដោយសុឆន្ទៈ ដើម្បីស្វែងយល់អំពីដំណើរការនៃការបង្រៀន និងការអនុវត្តតាមលក្ខខណ្ឌនានារបស់ក្រសួង ក៏ដូចជាការអនុវត្តតាមគរុកោសល្យម៉ុងតេស្សូរីនៅសាលាមត្តេយ្យសន្តិតេរេសា ដែលនៅកណ្តាលវាលស្រែមួយនេះ។

មានប្រសាសន៍ក្នុងពិធីដ៏ឱឡារិកនេះ លោកអូលីវីយេ ជាអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានជម្រាបជូនគណៈអធិបតី អំពីប្រវត្តិនៃការកសាងសាលា និងប្រវត្តិនៃគរុណកោសល្យម៉ុងតេស្សូរីនេះ។ លោកបន្តថា គរុកោសល្យនេះជួយ ឲ្យកុមារមានភាពរីកចម្រើនគ្រប់ផ្នែក គឺផ្លូវវិញ្ញាណ ផ្លូវកាយ និងផ្លូវចិត្ត។ កម្មវិធីនេះជួយឲ្យកុមារ មានភាពឯករាជ្យម្ចាស់ការ ចេះបញ្ចេញសមត្ថភាពរបស់គេរៀងៗខ្លួន។ លោកបន្តទៀតថា កុមារដែលមកចូលសាលាគឺគេមិនចង់ត្រលប់មកផ្ទះវិញទេ ព្រោះគេសប្បាយចិត្តក្នុងការរៀន គេចង់រីកចម្រើនផ្ទាល់ខ្លួន ដោយគ្រូគ្រាន់តែបង្កើតសម្ភារឧបទេសសម្រាប់ពួកគេ និងនៅពីក្រោយខ្នងរបស់គេតែប៉ុណ្ណោះ។ លោកអភិបាលបានសង្កត់ធ្ងន់ថា "សាលានេះ គឺនៅកណ្តាលវាលស្រែតែសាលាបានផ្តល់ឱកាសឲ្យកុមារបានទទួលការអប់រំដូចកុមារដទៃនៅទីប្រជុំជនក៏ដូចជានៅទីក្រុង"។


ថតដោយ លី សុវណ្ណា

ក្រោយពីបានស្តាប់របាយការណ៍នានារបស់គណៈគ្រប់គ្រង និងអ្នកគ្រូនៃសាលាមត្តេយ្យសន្តិតេរេសា ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន បានវាយតម្លៃខ្ពស់ពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំសាលាក៏ដូចជាគ្រូៗទាំងអស់ ដែលអនុវត្តបានយ៉ាងល្អតាមមេរៀនរបស់ក្រសួងអប់រំ និងម៉ុងតេស្សូរី។ ជាពិសេសសាលាមានបរិស្ថានល្អ មានអាគារ សម្ភារគ្រប់គ្រាន់ ប្រសើរជាងសាលាមួយចំនួននៅភ្នំពេញ ដែលបានអនុវត្តន៍កម្មវិធីម៉ុងតេស្សូរីដូចគ្នា។ ក្នុងនោះឯកឧត្តមរដ្ឋមន្ត្រី ក៏អំពាវនាវឲ្យឪពុកម្តាយចូលរួមយកចិត្តទុកដាក់គាំទ្រកុមារបន្ថែមទៀត។ ក្នុងនាមជាថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមរដ្ឋមន្ត្រីបានថ្លែងសេចក្តីអរគុណចំពោះលោកអភិបាលអូលីវីយេ និងសហការីដែលបានខិតខំយ៉ាងសកម្មក្នុងសកម្មភាពអប់រំនេះ។

*ដោយ លី សុវណ្ណា*

# ពិធីប្រកាសទទួលស្គាល់ មរណសាក្សី១៧នាក់ នៅប្រទេសឡាវជាអ្នកមានសុភមង្គលដ៏ពិតប្រាកដ

មនុស្សម្នាជាងមួយពាន់នាក់មកពីកន្លែងផ្សេងៗទូទាំងប្រទេសឡាវ និងអន្តរជាតិផង បានជួបជុំនៅវិសាល វិហារព្រះបេះដូងព្រះយេស៊ូកណ្តាលទីក្រុងវៀនច័ន្ទប្រទេសឡាវ ក្នុងពិធីអភិបូជាប្រកាសទទួលស្គាល់ មរណសាក្សីចំនួន ១៧នាក់នៅប្រទេសឡាវ ជាអ្នកមានសុភមង្គលដ៏ពិតប្រាកដ។

ពិធីនេះបានប្រព្រឹត្តទៅកាលពីថ្ងៃទី ១១ ធ្នូកន្លងទៅ ក្រោមអធិបតីភាព របស់លោកកាឌីណាល់ អូលែនដូ ហ្គេវីដូ អគ្គអភិបាល នៃកូតាបាតូ (ហ្វីលីភីន) និងមានវត្តមាន លោកអភិបាលជាច្រើនរូបក្នុងនោះក៏មានលោកអភិបាលទាំងបីអង្គពីកម្ពុជា ព្រមទាំងវត្តមានរបស់អាជ្ញាធរឡាវជាច្រើនរូបផងដែរ។

ពិធីបុណ្យបានចាប់ផ្តើមដោយពិធីដង្ហែ តាមប្រពៃណីឡាវ អ្នកចូលរួមមានសំលៀកបំពាក់ប្រពៃណីឡាវ និងប្រពៃណីជនជាតិភាគតិចឡាវផ្សេងៗគ្នា ក្នុងដៃមានកាន់រូបគំនូរមរណសាក្សីទង់ជាតិប្រទេសនានា កាន់ផ្កាដែលចងអំពីក្រដាសប្រាក់ឡាវ មានតន្ត្រីតាមប្រពៃណី ជនជាតិភាគតិចផ្សេងៗ ដង្ហែតាមផ្លូវសាធារណៈជុំវិញទីធ្លាវិសាលវិហារ ដែលមានចំងាយប្រមាណជា ៥០០ ម៉ែត្រ។

ព្រះសហគមន៍នៅប្រទេសឡាវមានគ្រីស្តបរិស័ទចំនួនប្រមាណជា ៤៥០០០ នាក់ក្នុងចំណោមប្រជាជនសរុបជិតប្រាំពីរលាននាក់។ មនុស្សម្នាចូលរួមពិធីបុណ្យដោយចិត្តរីករាយ ទោះបីពួកគាត់មិនបានចូលក្នុងព្រះវិហារក៏ដោយ តែពួកគាត់អាចមើលឃើញបានតាមកញ្ចក់ទូរទស្សន៍ដែលបានរៀបចំទុកជាស្រេច នៅក្នុងទីធ្លារបស់ព្រះវិហារ។

លោកបានកាឌីណាល់បានប្រកាសលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ដែលទទួលស្គាល់យ៉ាងនេះថា ៖ យើងបានពិនិត្យមើលឡើងវិញនូវឯកសារស្រាវជ្រាវរបស់ក្រសួងដែលទទួលបន្ទុកផ្នែកសន្តបុគ្គល។ ក្នុងឯកសិទ្ធិដែលបន្តពីក្រុមគ្រីស្តទូត យើងសូមទទួលស្គាល់ចាប់ពីពេលនេះតទៅចំពោះអ្នកបមម្រើរបស់ព្រះជាម្ចាស់ គឺលោកយ៉ូសែប ទៀន គឺជាអ្នកប្រកបដោយសុភមង្គលយ៉ាងពិតប្រាកដ។ លោក យ៉ូសែប ទៀន ជាបូជាចារ្យភូមិភាគជាសាក្សីនៃជំនឿ ជាគង្វាលដែលគាប់ព្រះហឫទ័យរបស់ព្រះយេស៊ូគ្រីស្ត និងសាក្សីដ៏ពិសេសអំពីព្រះរាជ្យនៃសេចក្តីយុត្តិធម៌ និងសេចក្តីសុខសាន្តរបស់ព្រះអង្គ លោកមិនស្ទាក់ស្ទើរក្នុងការបូជាជីវិត ដើម្បីប្រជាជន។


ថតដោយ សុធីរិទ្ធ

លិខិតរបស់សម្តេចប៉ាប បានបន្តថា ៖ យើងក៏ផ្តល់ងារដូចគ្នាដល់សហការីរបស់លោកទៀន ពោលគឺគ្រីស្តបរិស័ទជាគ្រហស្ថ ព្រមទាំង១១ នាក់ផ្សេងទៀតមកពីក្រុមសាសនទូត ក្រៅប្រទេសនាក្រុងប៉ារីស និងក្រុមបព្វជិត អ្នកថ្វាយបូជាចំពោះព្រះនាងម៉ារីមិនជំពាក់បាបដែលពួកគាត់ទាំងអស់សុទ្ធតែជាសាក្សីនៃជំនឿ។ ក្នុងសារលិខិតនេះក៏បានកំណត់យក ថ្ងៃទី១៦ ធ្នូ ជាថ្ងៃបុណ្យរំឭកដល់មរណសាក្សីទាំងនេះ ស្របតាមច្បាប់ព្រះសហគមន៍។

មរណសាក្សីទាំងនោះបានបូជាជីវិតក្នុងអំឡុងឆ្នាំ១៩៥៤ ដល់ ឆ្នាំ១៩៧០ ក្នុងពេលដែលប្រទេសឡាវធ្លាក់ក្នុងរបបកុម្មុយនីស្ត។ ក្នុងចំណោមមរណសាក្សីទាំងនោះ អ្នកមានវ័យក្មេងជាងគេ គឺថូម៉ាស ខាំភឿនដែលមានអាយុទើបតែ ១៦ឆ្នាំប៉ុណ្ណោះ។

នៅក្នុង ពិធីបុណ្យដ៏ឱឡារិក និងជាប្រវត្តិសាស្ត្រនេះក៏មាន សាច់ញាតិរបស់អស់លោកមរណសាក្សីទាំងនោះចូលរួមផងដែរ ហើយពិធីបុណ្យបាន បញ្ចប់វេលាថ្ងៃត្រង់ដោយការបរិភោគអាហារសាមគ្គីតាមប្រពៃណីជនជាតិឡាវ និងកុលសម្ព័ន្ធមួយចំនួនដែលមានក្នុងប្រទេសឡាវយ៉ាងរីករាយ។

*ដោយ ស្រីម៉ាច*

# កម្ពុជារំពឹងថា នឹងអាចប្រមូលផលស្រូវលើសពី ៥ លានតោននារដូវប្រមូលផលឆ្នាំនេះ

ប្រមុខរដ្ឋាភិបាលកម្ពុជាកាលពីពេលថ្មីៗនេះបានប្រកាសពីការព្យាករណ៍ដ៏ប្រសើរអំពីទិន្នផលស្រូវ នារដូវប្រមូលផលឆ្នាំនេះ ប៉ុន្តែទន្ទឹមនឹងការព្យាករណ៍ប្រកបដោយភាពវិជ្ជមានអំពីទិន្នផលស្រូវ អ្វីដែលជាចំណុចគួឲ្យយកចិត្តទុកដាក់នោះ គឺតម្លៃអង្ករកំពុងតែធ្លាក់ចុះ។

ថ្លែងនៅក្នុងពិធីសម្ពោធផ្លូវជាតិលេខ៧៦ កាលពីថ្ងៃទី២១ ខែតុលា សម្ដេចតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ឲ្យដឹងទៀតថា ឆ្នាំនេះស្រូវល្អតាមការប៉ាន់ស្មាន បន្ទាប់ពីទុកហូប និងទុកពូជស្រូវអាចនៅសល់ប្រមាណ ៥ លានតោន។

នេះគឺជាទិន្នផលមួយដ៏ខ្ពស់ គួរជាទីរំពឹង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលជាការព្រួយបារម្ភនោះ គឺការធ្លាក់ចុះនៃតម្លៃអង្ករទាំងនៅក្នុងទីផ្សារនៅក្នុងស្រុក តំបន់និងអន្តរជាតិ ។

ទីផ្សារស្រូវនៅក្នុងស្រុកត្រូវបានប្រជាកសិកររាយការណ៍ថា មានតម្លៃត្រឹមតែប្រមាណជា ៦០០ទៅ៦៥០រៀលប៉ុណ្ណោះនៅក្នុងមួយគីឡូក្រាម សម្រាប់ស្រូវក្រអូប ទោះបីជា រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសពីការអន្តរាគម ចំនួនប្រមាណជា ២៧លានដុល្លារ និងកំណត់តម្លៃស្រូវជាពិសេស គឺស្រូវក្រអូប នៅក្នុងតម្លៃទាបបំផុត៨៤០រៀលនៅក្នុងមួយគីឡូក៏ដោយ។

លោក យ៉ង់ សាំងកុមារ អ្នកជំនាញខាងកសិកម្មមួយរូប អ្នកនាំសារមិនអាចទំនាក់ទំនងបានទេ ប៉ុន្តែលោកបានធ្លាប់មានប្រសាសន៍ប្រាប់ប្រព័ន្ធផ្សព្វផ្សាយថា អ្វីដែលកសិករធ្លាប់រំពឹង គឺថាសម្រាប់ស្រូវធម្មតា គឺយ៉ាងហោចណាស់ក៏ចាប់ពី ១.០០០ រៀលដែរ នៅក្នុងមួយគីឡូ ប៉ុន្តែផ្ទុយមកវិញ គឺពួកគេបានទទួលក្រោម ៨០០ រៀល។ លោកបានជំរុញឲ្យរាជរដ្ឋាភិបាល ជួយទ្រទ្រង់វិស័យកសិកម្មជាពិសេស គឺកសិករបន្ថែមទៀត។

តម្លៃស្រូវនៅកម្ពុជាបានធ្លាក់ចុះ ដោយឡែកតម្លៃអង្ករនៅទីផ្សាយនៅក្នុងប្រទេសថៃ និងវៀតណាម ក៏បានធ្លាក់ចុះផងដែរ ហើយនៅពេលនេះ រដ្ឋាភិបាល និងអ្នកនយោបាយថៃ គឺកំពុងតែ សម្រុកធ្វើសកម្មភាពយកចិត្តទុកដាក់នឹងកសិករ។

រដ្ឋាភិបាលយោធាថៃបានប្រកាសអំពីកញ្ចប់ថវិការឧបត្ថម្ភទុន ដល់កសិករប្រមាណជា ១,១ ពាន់លាន ដុល្លារ ។

នៅក្នុងពេលនេះ អង្ករក្រអូបវៀតណាមបានធ្លាកចុះមកនៅត្រឹមតែ ពី ៥៧០ទៅ៦៥០ដុល្លារប៉ុណ្ណោះនៅក្នុងមួយតោន ខណៈដែលអង្ករក្រអូបថៃ បានធ្លាក់ចុះមកនៅត្រឹម ៩៨០ដុល្លារ ហើយគេរំពឹងថា នឹងបន្តធ្លាក់ចុះ ទៅដល់៧២៥ដុល្លារឯណោះនៅក្នុងមួយតោននៅដំណាច់ឆ្នាំនេះ។ អង្ករដែលឈ្មួញទិញពីកសិករថៃ គឺនៅក្នុងតម្លៃត្រឹមតែ ១៥ទៅ១៧ បាត ប៉ុណ្ណោះនៅក្នុងមួយគីឡូក្រម ខណៈដែលកសិករថៃចង់បានរហូតដល់ទៅពី២៤ទៅ២៥បាត នៅក្នុងមួយគីឡូក្រាម ។

ស្របពេលដែលការប្រមូលផលស្រូវបានឈានចូលមកដល់ ហើយតម្លៃនៅលីទីផ្សារនៅក្នុងស្រុក តំបន់ និងអន្តរជាតិកំពុងតែធ្លាក់ចុះបែបនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានអំពាវនាវឲ្យប្រជាកសិករទាំងអស់ត្រូវខិតខំថែរក្សាស្រូវទុកដាក់ឲ្យបានល្អ និងកុំប្រញាប់ប្រញាល់លក់ ដែលធ្វើឲ្យតម្លៃស្រូវធ្លាក់ចុះដោយសារស្រូវនៅសើម។

សម្ដេចតេជោ បានបញ្ជាក់ថា "ចំនួនស្រូវដែលមាននៅក្នុងប្រទេសក្នុងឆ្នាំនេះនឹងមានចំនួនច្រើនក្នុងពេលដែលពិភពលោក និងនៅក្នុងតំបន់កំពុងមានវិបត្តិនៃការធ្លាក់ចុះតម្លៃស្រូវមិនមែនគ្រាន់តែនៅកម្ពុជាទេ នៅប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសដទៃទៀតតម្លៃ អង្ករធ្លាក់ចុះទាំងអស់"។

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានធ្វើការអំពាវនាវទៅកាន់ប្រជាពលរដ្ឋថា "សូមបងប្អូនថែទាំស្រូវ ហាលស្រូវនេះទុកសិន នៅពេលស្រូវនេះឡើងថ្លៃចាំធ្វើការលក់ កុំលក់ស្រូវទាំងទទឹកធ្វើឲ្យឈ្មួញបង្អាប់ថ្លៃ ដោយសារតែយើងមិនបានហាលស្រូវឲ្យស្ងួតល្អដល់ពេលគេឃើញស្រូវសើមឈ្មួញចាប់ផ្ដើមទម្លាក់ថ្លៃ..."។

សម្ដេចតេជោបានបន្តថា ពិតមែនសម្ដេចយល់អំពីការលំបាករបស់ប្រជាពលរដ្ឋដែលមានតម្រូវការក្នុងការលក់ស្រូវយកលុយមកដើម្បីប្រើប្រាស់ និងសងបំណុលចំពោះស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ ក៏ប៉ុន្តែប្រសិនបើប្រជាពលរដ្ឋមានការអំណត់បន្តិចមិនត្រូវបានឈ្មួញបង្អាប់ថ្លៃនោះទេ។ ហើយក៏បានអំពាវនាវចំពោះស្ថាប័នមីក្រូហិរញ្ញវត្ថុដែលឲ្យប្រជាពលរដ្ឋខ្ចីសូមមេត្តាយោគយល់នូវការលំបាករបស់ប្រជាពលរដ្ឋដែលកំពុងមានការលំបាកអំពីបញ្ហាតម្លៃស្រូវចុះថោក។

គួររំលឹកថា កាលពីឆ្នាំ២០១៥កម្ពុជាធ្លាប់បានកំណត់គោលដៅជំរុញការនាំចេញអង្ករឲ្យបាន ១លានតោននៅឆ្នាំ២០១៥ ប៉ុន្តែគឺបានត្រឹមតែ ប្រមាណជា ៥ សែនតោនប៉ុណ្ណោះ ហើយដោយសារតែ បញ្ហាទីផ្សារនៅក្នុងឆ្នាំនេះការនាំចេញអង្ករកម្ពុជាក៏កំពុងតែមានសញ្ញាធាក់ថយនៅឡើយ។ ប៉ុន្តែសម្រាប់ឆ្នាំក្រោយកម្ពុជាអាចមានទីផ្សារច្រើន ។

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ឲ្យដឹងទៀតថា សម្រាប់ឆ្នាំ២០១៧ទីផ្សារដែលមានស្រាប់ យើងអាចនាំចេញទៅចិនបាន ២០ មុឺនតោន និងនាំចេញទៅប្រទេសវៀតណាម ៣០ មុឺនតោន ក្រៅពីនោះ នៅមានទីផ្សារនៅអឺរ៉ុបមួយចំនួន។

តាមរបាយការណ៍ផ្លូវការរបស់លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករបានបញ្ជាក់ថាការនាំចេញអង្កររបស់កម្ពុជាក្នុងរយៈពេល១០ខែ គឺមានបរិមាណ ជាង៤២មុឺនតោនមានការកើនឡើង ៣ភាគរយ ខណៈដែល ១០ខែ ឆ្នាំមុន គឺបានត្រឹមតែ ជាង ៤០ មុឺនតោន តែ ប៉ុណ្ណោះ។

យោងតាមតួលេខពី អង្គការស្បៀងអាហារនិងកសិកម្ម អង្គការសហប្រជាជាតិបានឲ្យដឹងថា សម្រាប់ឆ្នាំ២០១៦នេះតាមការរំពឹងទុកទិន្នផលស្រូវនឹងកើនឡើងប្រមាណជា ១,៤ភាគរយ ធៀបនឹងឆ្នាំ២០១៥ កន្លងទៅ ។ ទិន្នផលស្រូវសរុបនៅទូទាំងពិភពលោកគឺរំពឹងថា នឹងមានប្រមាណជា ៧៤៩,៧ លានតោន ឬគិតជាអង្ករមានប្រមាណជា ៤៩៧,៩ លានតោន។

*ដោយ អរិយបុត្រ*



ថតដោយ រិទ្ធី

# ហាឡូវីន ជាវប្បធម៌ថ្មីមួយកំពុងតែហាក់ចូលសង្គមកម្ពុជា



រូបថតពី ហ្វេសប៊ុក

ប្រទេសកម្ពុជាដែលត្រូវបានគេទទួលស្គាល់ថា ជាប្រទេសដែលគោរពសេរីភាពខាងជំនឿនិងសាសនានោះ ត្រូវបានគេដឹងថា កំពុងតែទទួលស្វាគមន៍នូវបុណ្យថ្មីមួយទៀតដែលត្រូវបានគេដឹងថា ហូរចេញមកពីអឺរ៉ុប គឺបុណ្យមួយដែលគេហៅថា ហាឡូវីន "halloween"។

កាលពីចុងខែតុលា ហាឡូវីន នេះត្រូវបានគេដឹងថា ត្រូវបានគេរៀបចំឡើងយ៉ាងផុលផុស និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ នៅតាមសាលាភាសាអន្តរជាតិ តាមសណ្ឋាគារ តាមភោជនីយដ្ឋានអឺរ៉ុបនានា នៅក្នុងប្រទេស ជាពិសេសគឺនៅរាជធានីភ្នំពេញ និងនៅតាមខេត្តសៀមរាប និងខេត្តព្រះសីហនុជាដើម។

ជុំវិញ ការរៀបចំនិងអបអរចំពោះពិធីបុណ្យបរទេសមួយនេះ លោក ហេង មុនីឫទ្ធិ ជាប្រជាពលរដ្ឋនៅខណ្ឌចំការមន មួយរូបបានឲ្យដឹងថា លោកហាក់ដូចជាមិនដែលកត់សំគាល់ទេ អំពីបុណ្យ ដែលគេហៅថា ហាឡូវីននេះពីមុនមក ប៉ុន្តែក្រោយពេលដែលលោក បានជូនចៅមករៀន នៅសាលារៀនភាសាអង់គ្លេស មកក៏បានឮបុណ្យនេះ។

លោកបានបញ្ជាក់ថា "អត់ដែលដឹងសោះបុណ្យនេះពីមុនមក តែពេលចៅគេធំដល់អាយុចូលរៀន មត្តេយ្យ ហើយជូនគេមកសាលា ទើបបានភ្ញាក់ផ្អើល ហើយសួរគេទៅទើបគេប្រាប់ថា ជាបុណ្យហាឡូវីននេះ "។

លោកបានបញ្ជាក់ថា "ដំបូងប្លែកស្មានតែសាលាគេមានកម្មវិធីអ្វី ពីព្រោះពេលដឹកចៅមកដល់ ឃើញក្មេងៗស្លៀកពាក់ចម្លែកៗ"។

លោកបានបន្តទៀតថា លោកមិនបានដឹងថា គេរៀបចំបុណ្យនេះយ៉ាងម៉េចទេ ប៉ុន្តែកាលពី ថ្ងៃទី៣១ តុលា ២០១៦ កន្លងទៅនេះ ពេលជូនចៅទៅសាលា គឺឃើញក្មេងៗជាសិស្សសាលានោះស្លៀកពាក់ តែងខ្លួន ពាក់មុខ ពាក់មាត់ចម្លែកៗ មានតាំងពីមុខខ្មោច មុខបិសាច អារធ្មើងមនុស្ស ទេពអប្សរ ជាដើម ខុសសព្វជង។

លោកបានបន្តទៀតថា ពេលជូនគេចូលទៅក្នុងសាលារៀន នៅក្នុងសាលា គឺមានការតុបតែងប្លែកៗ ជាច្រើននៅពេញទីធ្លាសាលា ហើយសូម្បីតែតាមបង្អួច និងនៅក្នុងថ្នាក់គឺមានបិទក្រដាស មានកាត់ក្រណាត់ចងរយើងរយោង មើលទៅប្លែក ហើយបើអត់មានភ្លើង ហើយស្ងាត់វិញ គឺសឹងតែ ដូចគុហា ឬល្អាង ភ្នំស្ងាត់កំបាំងមួយ។

លោកបានបន្តទៀតថា នៅពេលដែលទៅទទួលចៅមកវិញ គឺមុខមាត់ចៅ ត្រូវបានគេផាត់មុខ ប្លែក មានស្នាមគេគូសចង្កូមខ្មៅ ខណៈក្មេងៗ ឯទៀតក៏មិនខុសពីចៅខ្ញុំប៉ុន្មានដែរ។

លោក កែវ វិបុល ដែលជាអាណាព្យាបាល កុមារានិងកុមារី ពីររូប ក៏បានឲ្យដឹងដែរថា លោកបានស៊ាំនឹងហាឡូវីននេះហើយ ក្រោយពេលដែលបាននាំកូនទៅចុះឈ្មោះរៀនភាសាបរទេសនៅសាលាអន្តរជាតិ។

លោកបានបញ្ជាក់ថា "ដំបូងខ្ញុំក៏ភ្ញាក់ផ្អើលដែរ ប៉ុន្តែ២ ទៅ ៣ ឆ្នាំ មកនេះ វាដូចជាស៊ាំទៅហើយ ពីព្រោះបានឃើញវារាល់ឆ្នាំ ដូច្នេះក៏ចេះតែបណ្តោយកូនៗលេងសប្បាយនឹងពិធីបុណ្យបរទេស នេះជាមួយគេជាមួយឯងរាល់តែឆ្នាំទៅ។

លោកបានបញ្ជាក់ថា "បីឆ្នាំហើយ ខ្ញុំដាក់កូនចូលរៀនអង់គ្លេស ហើយតែដល់ខែតុលា ពួកគេតែងរំអុកសុំទិញខោអាវ ឬស្រោមមុខហាឡូវីន នេះហើយ"។

លោកបានបន្តថា នៅពេលដំបូងឃើញកូន មកវិញមុខមាត់ស្រមេម ស្រមាម លោកក៏ខឹងសាលា ប៉ុន្តែក្រោយពីសាកសួរពួកម៉ាក ឬមិត្តភក្តិ ទៅចម្លើយ មកវិញគឺដូចតែគ្នា ក៏ចេះតែបណ្តោយៗទៅ។

យុវតី មុន្នី កញ្ញានា ដែលកំពុងរៀនថ្នាក់ទី ១១ នៃសាលាចំណេះទូទៅ មួយនៅរាជធានីភ្នំពេញ បានឲ្យដឹងថា នាងក៏បានចូលរួមលេងសប្បាយកាលពីថ្ងៃហាឡូវីននេះផងដែរ ។

កញ្ញានា បានបន្តថា កន្លែងដែលនាងលេង និងរីករាយនាថ្ងៃបុណ្យហាឡូវីននេះ គឺនៅសាលាភាសា ដោយឡែកនៅសាលារៀនចំណេះទូទៅ គឺមិនបានលេងទេ។

កញ្ញានា បានបញ្ជាក់ថា "នៅសាលារដ្ឋគេអត់លេងផង តែនៅសាលាភាសា គេលេងសប្បាយណាស់។ នៅសាលារដ្ឋខ្ញុំគ្រាន់តែយក ធ្មេញខ្មោចមកពាក់ បន្លាចមិត្តភក្តិ តែប៉ុណ្ណោះ"។

លោកមុន្នីឫទ្ធិ បានឲ្យដឹងថា ប្រហែលជាការពិត ដោយសារតែចៅធំៗដែលរៀននៅសាលាវិទ្យាល័យទួលទំពូង ដូចជាមិនឃើញមាននរណា លេងហាឡូវីននេះទេ លើកលែងតែក្មេងៗនៅសាលាមត្តេយ្យអង់គ្លេស ជាពិសេស សាលាដែលថ្លៃៗ ។

ដោយសារតែទិដ្ឋភាពបែបនេះ លោកបានរំពឹងថាមិនយូរទេយ៉ាងច្រើន ៤ ទៅ ១០ឆ្នាំទៀត បុណ្យនេះនឹងសុះសាយពេញប្រទេស ដូចបុណ្យនៃក្តីស្រលាញ់ ឬបុណ្យសង្សារ និងបុណ្យបទេសជាច្រើនទៀត ដែលកំពុងតែបង្ហាញខ្លួននៅក្នុងសង្គមកម្ពុជា។

លោកបានបញ្ជាក់ថា "កាលសម័យខ្ញុំគ្មាននរណាស្គាល់បុណ្យនៃក្តីស្រលាញ់អីទេ តែឥឡូវនេះឲ្យតែដល់ថ្ងៃ១៤ កុម្ភៈ ទាំងខ្ញុំទាំងគេ រាប់ទាំងយាយវា ក៏ដឹងថ្ងៃនោះនឹងគេដែរ ដោយសារតែការសាបព្រោះអរិយធម៌បរទេសមកលើក្មេងៗបែបនេះ" ។

កាលពីថ្ងៃទី៣១ ខែតុលា កន្លងទៅថ្មីៗនេះ គឺមានការចូលរួមផុសផុលណាស់ ជាពិសេស នៅតាមសាលាអន្តរជាតិនានា នៅតាមក្រុមហ៊ុន និងនៅតាមសណ្ឋាគារមួយចំនួននៅក្នុងប្រទេស។ ដោយ នៅថ្ងៃនោះ យើងសង្កេតឃើញថា កុមារតូចៗ ក៏ដូចជាសិស្ស នៅសាលាអន្តរជាតិ និងអ្នកដែលចូលរួម អបអរបុណ្យនោះ ត្រូវបានគេលើកទឹកចិត្តឲ្យស្លៀកសម្លៀកបំពាក់ និងលាបមុខយ៉ាងចម្លែកៗ។

ហាឡូវីន គឺជាបុណ្យមួយនៃគ្រីស្តសាសនា ដែលឯកសារខ្លះបានអះអាងថា មានប្រភព នៅក្នុងមជ្ឈិមសម័យ នៅប្រទេស អៀកឡង់ ដែលគេបានរៀបចំឡើងដើម្បីរំលឹកដល់ អ្នកដែលស្លាប់នៅចុងរដូវ ក្តៅ និងដើមរដូវធ្លាក់ទឹកកក ពោលគឺនៅក្នុងពេលដែល ដែនដីរបស់គេ មានស្ថានភាពពាក់កណ្តាលងងឹត ពាក់កណ្តាលថ្ងៃ។ ក្រោយមកបុណ្យនេះក៏បានរីករាលដាលនឹងជ្រួតជ្រាបទៅ តំបន់ផ្សេងៗ ហើយក៏មកដល់ប្រទេសកម្ពុជាផងដែរ ។

បើប្រៀបធៀបនឹងបុណ្យនៃក្តីស្រលាញ់ និង បុណ្យតាមវប្បធម៌បច្ចឹមប្រទេសឯទៀត វាហាក់ដូចជាថ្មីជាងគេបន្តិច ប៉ុន្តែ វាក៏មិនជាថ្មីណាស់ណាដែរ ដោយសារតែ នៅតាមសាលាមួយចំនួន គឺគេបានរៀបចំជាហូរហែរយូរដែរហើយ។ រហូតមកដល់ពេលនេះ គ្មាននរណាដឹងថា ទៅថ្ងៃមុខវាយ៉ាងណានោះទេ ?

ក្រៅពីបុណ្យនេះនៅមាន បុណ្យ និងពិធីសាសនាផ្សេងៗ ជាច្រើនដែលត្រូវបានគេនាំមករៀបចំនិងប្រារព្ធឡើង នៅក្នុងប្រទេសកម្ពុជា។

*ដោយ អរិយបុត្រ*

# និស្សិតចំនួន៦៤នាក់ នៃវិទ្យាស្ថានសន្តប៉ូលទទួលសញ្ញាបត្រថ្នាក់បរិញ្ញា



ថតដោយ លី សុវណ្ណា

និស្សិតចំនួន៦៤នាក់ នៃវិទ្យាស្ថានសន្តប៉ូលបានបញ្ចប់ការសិក្សារបស់ខ្លួនដោយជោគជ័យ ដែលមានដូចជា ថ្នាក់បរិញ្ញាបត្រព័ត៌មានវិទ្យា ថ្នាក់បរិញ្ញាបត្រកសិកម្ម ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស និង ថ្នាក់បរិញ្ញាបត្រទេសចរណ៍។ ពិធីចែកសញ្ញាប័ត្រនេះ បានប្រារព្ធទៅនៅវិទ្យាស្ថានសន្តប៉ូល មានទីតាំងស្ថិតក្នុងភូមិអង្គគី ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ក្រោមអធិបតីរបស់ ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន ទេសរដ្ឋមន្ត្រីទទួលបេសកកម្មពិសេស និងជាអនុប្រធាននៃក្រុមប្រឹក្សាស្ថារនិងអភិវឌ្ឍន៍កម្ពុជា និងលោកអូលីវីយេ ដ្មីតអីស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងជានាយកវិទ្យាស្ថានសន្តប៉ូល ដោយមានការចូលរួមពីសំណាក់អាជ្ញាធរ មាតាបិតា អាណាព្យាបាល ព្រមទាំងសាស្ត្រាចារ្យ បុគ្គលិកសិក្សា និងនិស្សិតនៃវិទ្យាស្ថានសន្តប៉ូលយ៉ាងច្រើនកុះករ។

ក្នុងឱកាសនោះ លោកអូលីវីយេនាយកវិទ្យាស្ថានសន្តប៉ូល បានថ្លែងអំណរគុណដល់ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន ដែលបានចូលរួមសម្រួលដល់ដំណើរនៃការបើកវិទ្យាស្ថានរហូតមកដល់បច្ចុប្បន្ន។ លោកនាយកក៏បានបន្តថា សព្វថ្ងៃវិទ្យាស្ថានសន្តប៉ូល មានកិច្ចសហការជាមួយសាកលវិទ្យាល័យធំៗនៃបណ្ដាលប្រទេសមួយចំនួនដូចជា អូស្ត្រាលី ហ្វីលីភីន អ៊ីតាលី តាន់ហ្សានី និងនៅប្រទេសកូរ៉េជាដើម។ ផ្នែកមួយទៀតគឺ អំពីជីវិតនិស្សិត ធ្វើយ៉ាងណាដើម្បីឲ្យនិស្សិតរីកចម្រើន ទាំងស្មារតី និងចំណេះដឹងដោយមានឯករាជ្យម្ចាស់ការតាមរយៈភារកិច្ចរបស់ការិយាល័យនិស្សិតរួមជាមួយនឹងមណ្ឌលស្នាក់នៅរបស់និស្សិតដែលមកពីឆ្ងាយ។ មួយផ្នែកទៀត គឺរៀបចំកម្មសិក្សារបស់និស្សិតនៅវិទ្យាស្ថានសន្តប៉ូល ត្រូវបានយកចិត្តយ៉ាងសំខាន់ក្នុងការរៀបចំ ស្វែងរកកន្លែងដើម្បីឲ្យនិស្សិតចុះកម្មសិក្សានៅតាមស្ថាប័ននានា។

ទោះបីជាសាកលវិទ្យាល័យមួយចំនួននៅកម្ពុជាបានលប់ចោលនូវការសរសេរនិក្ខេបបទបញ្ចប់ការសិក្សា ជំនួសដោយប្រលងបញ្ចប់ក៏ដោយ ក៏វិទ្យាស្ថានសន្តប៉ូលរក្សាឲ្យនៅដដែល អំពីការសរសេរនិក្ខេបបទ ដោយលោកនាយកបានលើកឡើងពីសារសំខាន់យ៉ាងនេះថា ការសរសេរនិក្ខេបបទ គឺជួយឲ្យនិស្សិតមានសមត្ថភាពស្រាវជ្រាវ និងមានស្នាដៃថ្មី។ និស្សិតជាច្រើនមានការងារធ្វើ ជាមួយស្ថាប័នទាំងឡាយដែលគេបានចុះកម្មសិក្សាជាមួយ ព្រោះស្ថាប័នទាំងនោះបានឃើញពីស្ថារដៃ និងសមត្ថភាពផ្ទាល់របស់និស្សិត។ ទស្សនវិស័យផ្នែកទីបួន លោកនាយកបានលើកឡើងថាគឺ ការអភិវឌ្ឍន៍ ធ្វើយ៉ាងឲ្យមានកម្លាំង និងភាពរីកចម្រើន។ តាមផែនការព្រះសហគមន៍កាតូលិកមានគំរោងបើកមន្ទីរពេទ្យកាតូលិកនៅភ្នំពេញ ហេតុនេះវិទ្យាស្ថានសន្តប៉ូល នឹងបើកសាលាសម្រាប់បណ្ដុះបណ្ដាលគិលានុបដ្ឋាក និងគិលានុបដ្ឋាកយិការ សម្រាប់គំរោងមន្ទីរពេទ្យនេះក្នុងឆ្នាំ២០២២។ លោកនាយកក៏បានរក្សានិងជំរុញជានិច្ចនូវ ថ្នាក់ជំនាញឯកទេសពិតប្រាកដ លើវិស័យកសិកម្ម និងទេសចរណ៍។ ក្នុងទស្សនវិស័យនេះ ក៏មិនភ្លេចការបញ្ចូលប្រជាជនពលរដ្ឋក្នុងសហគមន៍ឲ្យចូលរួមដើម្បីឲ្យគេមានការងារធ្វើដែលជួយឲ្យជីវភាពរបស់គេរីកចម្រើនក្នុងសហគមន៍ក៏ដូចជាសង្គមកម្ពុជាទាំងមូលព្រោះអាចកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋក្នុងបាន។

ក្នុងនាមជាគណអធិបតីក្នុងអង្គពិធី ឯកឧត្តមបណ្ឌិតច័ន្ទ សារុន បានកោតសរសើរ និងអរគុណដល់ព្រះសហគមន៍កាតូលិក ជាពិសេសលោកអភិបាលអូលីវីយេ ដែលបានចូលរួមកសាងសង្គមតាមរយៈការកសាងធនធានមនុស្សនៅកម្ពុជា។ សកម្មភាពទាំងនេះ ពិតជាបានជួយកាត់បន្ថយភាពក្រីក្រនៅកម្ពុជាពិតប្រាកដមែន។ ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី ក៏បានប្រកាសឧបត្ថម្ភដល់វិទ្យាស្ថានតាមការស្នើរបស់លោកនាយកវិទ្យាស្ថានសន្តប៉ូល មានដូចជា៖ ផ្ដល់សម្ភារៈសិក្សាដល់វិទ្យាស្ថានសន្តប៉ូល។ បង្កើតមូលនិធិដល់សិស្សពូកែ នៃវិទ្យាល័យសន្តហ្វ្រង់ស្វ័រ និងវិទ្យាស្ថានសន្តប៉ូល។ ផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ អាចបន្តការសិក្សានូវថ្នាក់ឧត្តមបាន។ គាំទ្រដល់ការលើកកំពស់សមត្ថភាពរបស់សាស្ត្រាចារ្យ តាមរយៈឧបត្ថម្ភ លើកម្មសិក្សា និងការចូលរួមសិក្ខាសាលានានា។ អំពីកម្មសិក្សាសម្រាប់ឯកទេសកសិកម្ម ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី ច័ន្ទ សារុនក៏បានជម្រុញឲ្យវិទ្យាស្ថានសន្តប៉ូល ចាប់ផ្ដើមមានទំនាក់ទំនងជាមួយប្រទេសអ៊ីស្រាអែល ដែលប្រទេសនេះមានឯកទេសខ្ពស់ខាងផ្នែកកសិកម្មទំនើប ដើម្បីធ្វើការបញ្ជូននិស្សិតទៅសិក្សានៅទីនោះ។ ដើម្បីអបអរសាទរដល់និស្សិតជ័យលាភីទាំង៦៤រូប ឯកឧត្តមបណ្ឌិត ច័ន្ទ សារុន បានផ្ដល់ថវិកា ដល់និស្សិតដែលទទួលជ័យលាភីក្នុងម្នាក់ៗចំនួនបីម៉ឺនរៀល ព្រមទាំងបានលើកទឹកចិត្តដល់សាស្ត្រាចារ្យ និងបុគ្គលិកសិក្សាចំនួន៥៨នាក់ក្នុងម្នាក់ៗទទួលបានថវិការចំនួនប្រាំម៉ឺនរៀល និងសារុងមួយ។ ពិធីនេះបានបញ្ចប់ដោយគណអធិបតីចែកសញ្ញាបត្រដល់តំណាងនិស្សិតតាមមហាវិទ្យាល័យនីមួយៗ ប្រកបដោយភាពសប្បាយរីក និងស្និទ្ធស្នាលជាទីបំផុត។

គួរបញ្ជាក់ផងដែរថា វិទ្យាស្ថានសន្តប៉ូល គឺជាឧត្តមសិក្សាតែមួយគត់នៅកម្ពុជារបស់សាសនាគ្រីស្តនិកាយកាតូលិក។ វិទ្យាស្ថាននេះបានបង្កើតឡើងក្នុងឆ្នាំ២០០៩ រហូតដល់សព្វថ្ងៃ ដែលមានមហាវិទ្យាល័យព័ត៌មានវិទ្យា មហាវិទ្យាល័យកសិកម្ម មហាវិទ្យាល័យទេសចរណ៍ និងមហាវិទ្យាល័យសង្គមកិច្ច និងមានថ្នាក់បរិញ្ញាប័ត្ររងជំនាញឯកទេសចំនួនពីរផ្សេងទៀតដែរ។ ចំពោះនិស្សិតដែលបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានសន្តប៉ូលកន្លងមកបានទទួលការងារស្មើរល្អ និងមានចំណូលខ្ពស់១០០ភាគរយ។

*ដោយ លី សុវណ្ណា*

# នរណាក៏អាចក្លាយជាអ្នកវិភាគបានដែរឲ្យតែយើងមានឆន្ទះ


ថតដោយ អរិយបុត្រ

*អ្នកវិភាគសង្គមអាចថា ជាអ្នកដែលកំពុងតែចូលរួមចំណែកយ៉ាងសកម្មមួយនៅក្នុងការអភិវឌ្ឍន៍សង្គម ដូច្នេះដើម្បីឲ្យដឹងនិងដើម្បីឲ្យជ្រាបលើការងារនេះ អ្នកនាំសារសូមអនុញ្ញាតណែនាំមិត្ត អ្នកអានឲ្យជួបលោក **ហង្ស វិទូ** ដែលជាអ្នកវិភាគវ័យក្មេងមួយរូបនៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ។*

***អ្នកនាំសារ:*** តើការងារវិភាគនេះជាកិច្ចការអ្វីទៅ?

***លោកហង្ស វិទូ:*** ការវិភាគ គឺជាការព្យាករណ៍ ឬក៏ជាការនិយាយអ្វីទៅតាមការសិក្សាស្រាវជ្រាវ។ ជាទូទៅអ្នកវិភាគនៅក្នុងស្រុកខ្មែរដែលខ្ញុំបានមើលឃើញ គឺភាគច្រើនជាអ្នកវិភាគឲ្យគណបក្សនយោបាយ ខាងរដ្ឋាភិបាល ទូរទស្សន៍មួយចំនួនក៏មានអ្នកវិភាគរបស់គេផងដែរ។ អ្នកវិភាគជាអ្នកដែលផ្តល់ទិន្នន័យដល់ប្រជាពលរដ្ឋពិតប្រាកដ ឬជាព័ត៌មានបញ្ចើចបញ្ចើល ឬជាការបន្ថែម ប៉ុន្តែនៅសង្គមកម្ពុជាគឺខ្វះអ្នកវិភាគដែលឯករាជ្យ ដោយភាគច្រើនគឺវិភាគគាំទ្រតែគណបក្ស កាន់អំណាចហើយ បើសម្រាប់គណបក្សប្រឆាំងវិញក៏ដូចគ្នា។ ការវិភាគនេះ ជាការផ្តល់ព័ត៌មានដ៏ជាក់លាក់មួយ តាមរយៈការស្រាវជ្រាវ និងតាមរយៈរបកគំហើញ។

***អ្នកនាំសារ:*** បើតាមការអះអាងរបស់លោក អ្នកវិភាគនៅកម្ពុជាមានច្រើន ចុះអ្នកវិភាគសង្គមវិញយ៉ាងម៉េចដែរ?

***លោកហង្ស វិទូ:*** អ្នកវិភាគសង្គម គឺអាចមានភាពសុក្រិតជាង ហើយឯករាជ្យ ប៉ុន្តែវាមិនប្រាកដថា សុក្រិតទាំងអស់នោះទេ។ យើងទទួលស្គាល់ថា នៅពេលដែលស្រាវជ្រាវក៏អាចមាននូវភាពខុសឆ្គងមួយចំនួន ដែលយើងមិនហ៊ាននិយាយថា ត្រូវ ១០០ភាគរយនោះទេ។ ការវិភាគសង្គម គឺជាការងារដែលគេអាចវិភាគលើបញ្ហាជាច្រើនដូចជា បញ្ហាព្រំដែន ចរាចរណ៍ ភាពក្រីក្រ អំពើពុករលួយជាដើម។ អ្នកវិភាគដែលបានសិក្សាស្រាវជ្រាវ គឺវាប្រសើរជាងអ្នកវិភាគណា ដែលអានកាសែត ហើយមើលបណ្តាញសង្គមយកមកវិភាគ ។

***អ្នកនាំសារះ*** តើមូលហេតុអ្វីបានជាលោកចង់ក្លាយជាអ្នកវិភាគបែបនេះ ហើយបើតាមវ័យ លោកទើបតែមាន អាយុ ២៦ ឆ្នាំ?

***លោកហង្ស វិទូ:*** អ្នកវិភាគមានច្រើនដូចដែលខ្ញុំបានរៀបរាប់ខាងលើមក ហើយចំណុចមួយទៀត មូលហេតុទីពី គឺដោយសារតែខ្ញុំមិនទុកចិត្ត។ បច្ចុប្បន្ននេះមានអ្នករិះគន់ខ្ញុំថា ជាអ្នកវិភាគរិះគន់ រដ្ឋាភិបាល និងមេដឹកនាំ ប៉ុន្តែបើមើលនិងសង្កេតឲ្យជាក់ អ្នកដែលខ្ញុំវិភាគរិះគន់ខ្លាំងគឺ គណបក្សប្រឆាំងតែម្តង។ ប៉ុន្តែការរិះគន់របស់ខ្ញុំ គឺជាការរិះគន់ស្ថាបនា មិនមែនឲ្យគេអាប់ឱននោះទេ។ យើងយល់ថា អ្នកនយោបាយគឺលោកធ្វើការដើម្បីជាតិ ប៉ុន្តែកំហុសឆ្គងមួយចំនួនដែលយើងត្រូវតែដឹង។

***អ្នកនាំសារ:*** ដើម្បីក្លាយជាអ្នកវិភាគដោយឯករាជ្យមួយរូប តើយើងត្រូវរៀបចំខ្លួនយ៉ាងដូចម្តេច?

***លោកហង្ស វិទូ:*** ជាទូទៅ សម្រាប់ខ្ញុំគឺខ្ញុំចូលចិត្តអក្សរសាស្ត និងទស្សនវិទ្យា ដល់ខ្ញុំចូលរៀន ទី៧ និងទី៨ ខ្ញុំក៏ចូលចិត្តផ្នែកនយោបាយ។ អ្នកវិភាគមានគោលការណ៍៤ ដែលទី១ គឺ យើងជាមនុស្សដែលចូលចិត្តអានច្រើនបំផុត ពោលគឺសៀវភៅនៅជាប់នឹងដៃ។ សៀវភៅ គឺជាប្រភពពុទ្ធិមួយរបស់មនុស្ស ។ ទីពីរ គឺរៀនឲ្យបានច្រើននូវទស្សនវិជ្ជា ដោយសារតែ វាគឺជាបិតានៃវិទ្យាសាស្ត្រផ្សេងៗនៅក្នុងសង្គមមនុស្ស។ ទីបី គឺឯកសារស្រាវជ្រាវឲ្យបានច្បាស់លាស់ ឧទាហរណ៍បើយើងជាអ្នកវិភាគផ្នែកសេដ្ឋកិច្ច គឺត្រូវតែមានទិន្នន័យ មានព័ត៌មាននៅក្នុងដៃឲ្យបានច្បាស់លាស់។ មិនមែនដើរទៅឃើញហើយចេះតែថា នោះទេ។ ចំណុចទីបួន គឺឯករាជ្យ និងឧត្តមគតិ។

***អ្នកនាំសារ:*** តើនរណាខ្លះអាចនឹងក្លាយខ្លួនជាអ្នកវិភាគដូចជា លោក បាន?

***លោកហង្ស វិទូ:*** អ្នកណាក៏អាចក្លាយជាអ្នកវិភាគបានដែរ។ អ្នកដែលរៀនគណិតវិទ្យាក៏អាចក្លាយ ជាអ្នកវិភាគបានដែរ ប៉ុន្តែចំណុចសំខាន់ថា តើគាត់មានចិត្តក្នុងការវិភាគ ឬអត់ ហើយសន្សំចំណេះដឹងទូទៅច្រើន។

***អ្នកនាំសារ:*** ចុះបញ្ហាផលប្រយោជន៍វិញ?

***លោកហង្ស វិទូ:*** សម្រាប់ខ្ញុំមកដល់ពេលនេះ ៦ ឆ្នាំហើយ ខ្ញុំមិនដែលទទួលថវិកាសូម្បីមួយដុល្លារ ពីការវិភាគ ពេលតាំងពីខ្ញុំនៅអំឡុងពេលសិក្សានៅថៃរយៈពេល៤ ឆ្នាំចុងក្រោយ និងមកនៅកម្ពុជា ២ ឆ្នាំចុងក្រោយនេះ។ នេះគឺជាកិច្ចការជួយសង្គម។ រហូតមកដល់ពេលនេះ ចំណូលដែល ខ្ញុំទទួលបាន គឺពីការងារក្រៅម៉ោងខ្លះពីការងារបង្រៀន...។ នៅកម្ពុជាក៏មានអ្នកវិភាគមួយចំនួន ដែលវិភាគដើម្បីកេរ្តិ៍ឈ្មោះ ការងារលាភសក្ការៈណាមួយដែរ ប៉ុន្តែសង្គមខ្មែរក៏គួរតែ មានអ្នក និយាយពីការពិតខ្លះដែរ។

***អ្នកនាំសារ:*** តើអ្វីដែលជាបញ្ហាប្រឈម ជាក់ស្តែងសម្រាប់អ្នកវិភាគ? តើលោកធ្លាប់បារម្ភករណី ដូចជា លោក បណ្ឌិត កែម ឡី ទេ?

***លោកហង្ស វិទូ:*** សម្រាប់អ្នកខ្លះគេខ្លាច ប៉ុន្តែសម្រាប់ខ្ញុំក៏ខ្ញុំមិនគិតថា ខ្ញុំគឺជាអ្នកហ៊ានអ្វីដែរ ប៉ុន្តែគ្រាន់តែគិតថា ជីវិតដែលយើងកើតមក ហើយអត់បានជួយអ្នកដទៃ គឺជាជីវិតដែលអត់មានន័យ។ ខ្ញុំគិតថា បើជីវិតគ្រាន់តែកើតមកហើយបម្រើតែការងារ ដែលស៊ីផុះ ស៊ីផុះ គឺជីវិតគ្មានន័យទេ។ រស់នៅជាមនុស្សដែលត្រឹមត្រូវ ១ថ្ងៃ វាប្រសើរជាងមនុស្សរស់នៅ១០០ ឆ្នាំនាំឲ្យធ្ងន់ផែនដែរ។

***អ្នកនាំសារ:*** លោកមានវ័យត្រឹមតែ ២៦ឆ្នាំទេ សួរថា តើលោកបានបន្សល់ទុកនូវស្នាដៃ អ្វីខ្លះហើយសម្រាប់សង្គមនាពេលនេះ?

***លោកហង្ស វិទូ:*** ខ្ញុំធ្លាប់សរសេរសៀវភៅភាសាថៃចំនួន៣ក្បាល និងភាសាអង់គ្លេស ២ក្បាល ហើយថ្មីៗនេះក៏បានសរសេរសៀវភៅទាក់ទងនឹងលោកបណ្ឌិត កែម ឡី ហើយនៅឆ្នាំខាងមុខ នឹងចេញសៀវភៅអង់គ្លេស មួយច្បាប់ទៀត អំពី លោក បណ្ឌិតកែម ឡីដែរ។ ដោយឡែក សម្រាប់ សៀវភៅជុំវិញលោកបណ្ឌិតកែម ឡី គឺថវិការដែលប្រមូលបាន នឹងបរិច្ចាគជូនមន្ទីរពេទ្យគន្ធបុប្ផា ប្រពន្ធលោក កែម ឡី និងសហគមន៍ក៏ដូចជាការងារស្រាវជ្រាវមួយចំនួន។

## លោក ហង្ស វិទូ អ្នកវិភាគបញ្ហាសង្គមមានវ័យត្រឹម២៦ ឆ្នាំ

លោក ហង្ស វិទូ គឺជាយុវជនមួយរូបដែលមានកំណើតពីគ្រួសារកសិកររស់នៅលើដីគេមួយនៅក្នុង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង។

លោក គឺជាកូនទីបីនៅក្នុងគ្រួសារតែមានបងប្អូនប្រុសចំនួន ៤ នាក់ហើយលោកបានបញ្ចប់ការសិក្សាអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយនៅសិង្ហបុរី និងបានបញ្ចប់ការសិក្សា បរិញ្ញាប័ត្របីនៅក្នុងប្រទេសថៃ ពីសាកលវិទ្យាល័យធម្មាសាត។

លោកបានបញ្ជាក់ថា "ខ្ញុំចាំបានថាកាលនៅក្មេងថ្នាក់ទី៦ ដល់ទី៨ ខ្ញុំធ្លាប់ដើរទៅរៀន ១០គម មកវិញ ១០គម នៅក្នុងមួយថ្ងៃដើម្បីរៀន។ ជីវិតរបស់ពួកខ្ញុំ គឺលំបាកវេទនាណាស់"។

លោកបានបន្តថា ម្តាយរបស់លោក ជាកសិករដែលមិនចេះអក្សរទេ ហើយកត្តាដែលបានជំរុញឲ្យ ពួកលោកខំរៀននោះ គឺដោយសារតែ ឪពុកម្តាយលោកពោលពាក្យតែមួយម៉ាត់ទេ "បើសិនកូនមិនចង់ពិបាកត្រូវតែខំរៀន"។

លោក ហង្ស វិទូ បានទទួលបរិញ្ញាប័ត្រច្បាប់ វិទ្យាសាស្រ្តនយោបាយ និងអក្សរសាស្ត្រអង់គ្លេស ពីសកលវិទ្យាល័យធម្មាសាធ។

លោកបានបន្តថា លោកបានរៀនភាសា និងរៀនចំណេះទូទៅ ដោយមិនដែលបានស្គាល់ការរៀនគួរនឹងគេនោះទេ ពីព្រោះអត់លុយ តែខំរៀនដល់ពេលប្រឡងបាក់ឌុបក៏បាននិទ្ទេស បេ។

លោកបានបញ្ជាក់ថា "គ្មានអ្វីជោគជ័យជាងការតាំងចិត្ត ហើយចង់ និងស្រលាញ់នោះទេ "។

*ដោយ អរិយបុត្រ*

# ពលករខ្មែរ៤រូបជីវិតថ្លៃមានសំណាងមានជីវិតក្រោយចោរសមុទ្រចាប់៥ឆ្នាំ



ថតដោយ ឡុងសម្ផស្ស

ដោយសារតែជីវភាព ពលករខ្មែរជាច្រើនបានបង្ខំចិត្តស្កាត់ដើររកការងារធ្វើនៅក្រៅប្រទេស រហូតដល់អ្នកខ្លះត្រូវបាត់បង់ជីវិត ខ្លះជួបឧបទ្ទវហេតុពិការ ខ្លះមានជំងឺ ដើម្បីបំពេញបំណងកែប្រែជីវភាព និងលក្ខខណ្ឌជីវិតជូនគ្រួសារ ដោយឡែកពលករខ្មែរបួនរូប មានវាសនាដ៏សែនគ្រោតគ្រាតពេល គឺមិនត្រឹមតែបានការងារធ្ងន់ធ្ងរ និងគ្រោះថ្នាក់នោះទេ គឺថែមទាំងត្រូវចោរសមុទ្រចាប់ពង្រត់រហូតដល់អាហ្វ្រិកដល់ទៅ ៥ឆ្នាំថែមទៀត។

បុរសដែលជាពលករខ្មែរទាំងបួនរូប ដែលអាចមានវាសនារួចជីវិតនឹងត្រូវបានសង្គ្រោះវិលត្រឡប់មកកាន់មាតុប្រទេសវិញ ក្រោយរស់នៅខ្វាត់ព្រាត់នៅលើសមុទ្រ និងរស់ក្រោមលក្ខខណ្ឌជាជនរងគ្រោះ ដែលត្រូវចាប់ជម្រិតជាច្រើនឆ្នាំ ត្រូវបានគេដឹងថា មានឈ្មោះ ខ វ.ធ អាយុ២៦ឆ្នាំ មានស្រុកកំណើត និងរស់នៅខេត្តកំពង់-ចាម គ គ.ហ អាយុ ៣៣ ឆ្នាំ មានទីលំនៅក្នុងខេត្តក្រចេះ លោក ង ភ.ម.ន. អាយុ ៣៣ ឆ្នាំ និងលោក ញ.ម. ស.ស អាយុ ៣៧ ឆ្នាំ រស់នៅក្នុងខេត្តកំពង់ឆ្នាំង។

ពួកគេទាំង៤ ត្រូវបានជួយសង្គ្រោះនិងមានវាសនាវិលត្រឡប់មកមាតុប្រទេសវិញ កាលពីថ្ងៃទី៣០ ខែតុលា កន្លងទៅក្រោមជំនួយពីអាជ្ញាធរកម្ពុជា និងអង្គការជាដៃគូ មួយចំនួន ដែលនៅក្នុងនោះ ក៏មានអង្គការការិតាស ដែលជាអង្គការមនុស្សធម៌របស់ព្រះសហគមន៍កាតូលិកមួយផងដែរ។

ក្រោយពីត្រូវបានក្រុមចោរសមុទ្រនៅប្រទេសសូម៉ាលីចាប់ធ្វើជាចំណាប់ខ្មាំងអស់រយៈពេលជិត ៥ឆ្នាំ ពលករខ្មែរទាំង ៤នាក់ នាថ្ងៃទី០១ ខែវិច្ឆិកា បានរៀបរាប់អំពីដំណើរជីវិតដ៏សែនគ្រោះថ្នាក់របស់ខ្លួននៅលើទូកនេសាទត្រីពីប្រទេសមួយ ទៅប្រទេសមួយ រហូតដល់ជីវិតស្ថិតនៅក្រោមកណ្ដាប់ដៃរបស់ក្រុមចោរសមុទ្រថា ពួកគេមិនគិតថា មានជីវិតអាចវិលត្រឡប់មកជួបជុំគ្រួសារនៅមាតុប្រទេសវិញនោះទេ។

ពលករ ង ភ.ម.ន ជាពលករដែលជួបហេតុការណ៍នេះ បានរៀបរាប់អំពីជីវិតខ្លួនថា ពីដំបូងពួកគេបានចាកចេញពីកម្ពុជាទៅធ្វើជាពលករលើទូកនេសាទរបស់ក្រុមហ៊ុនតៃវ៉ាន់មួយ ពោល គឺនៅលើកប៉ាល់ឈ្មោះ ណាហាម ៣( Naham 3) ដោយត្រូវធ្វើការពី ១៨ម៉ោង ទៅ ២១ម៉ោងដោយទទួលប្រាក់ខែត្រឹមតែ ១៥០ ដុល្លារប៉ុណ្ណោះ។

លោកបានរៀបរាប់អំពីដំណើរជីវិតថាពួកគាត់ចាកចេញពីកម្ពុជាឆ្ពោះទៅកាន់ប្រទេសសិង្ហបុរី រួចបន្តទៅដល់ប្រទេសឥណ្ឌាហើយចុងក្រោយទៅដល់ប្រទេសម៉ារីទូសរួចក៏ចុះកប៉ាល់នៅទីនោះ ហើយឆ្លងចូលដែនសមុទ្រប្រទេសសូម៉ាលី។

ក្រោយពេលធ្វើការបានជាង ១ឆ្នាំ នៅលើទូកនេសាទនោះនៅខែមីនា ឆ្នាំ២០១២ ក្រុមចោរសមុទ្រនៅប្រទេសសូម៉ាលីបានបើកអូរប័រតូចមួយមកជិតកប៉ាល់ណា-ហាម៣ ហើយបានបាញ់សម្លាប់អ្នកបើកបរកប៉ាល់។

ពលកររងគ្រោះរូបនេះបន្តថា ក្រោយពេលបាញ់សម្លាប់អ្នកបើកបរហើយនៅសល់មនុស្ស ២៧នាក់ទៀតនៅលើកប៉ាល់ ប៉ុន្តែក្រុមចោរមិនចាប់ជាងម៉ាស៊ីនទេ គឺចាប់តែមនុស្ស ២៦នាក់ប៉ុណ្ណោះ។

ពលកររងគ្រោះមួយរូបទៀត បានឲ្យដឹងថាគាត់មិនដែលគិតថា អាចរួចជីវិតពីក្រុមចោរនោះទេដោយសារទឹកប្រាក់ដែលពួកវាទាមទារមានចំនួនច្រើន។ លោកថា ចំណាប់ខ្មាំងទាំងអស់ត្រូវធ្វើការដើម្បីជាថ្នូរនឹងអាហារទោះបីជាការងារទាំងនោះមិនសូវជាធ្ងន់ធ្ងរក៏ដោយ។

លោកបន្តថានៅថ្ងៃចុងក្រោយពួកគេបានយល់ព្រមដោះលែង ដោយត្រូវធ្វើដំណើររយៈពេល៧ ម៉ោងពីជំរំឃុំឃាំងក្នុងព្រៃនោះទៅទីក្រុង ហ្គាល់កាយ៉ូ (Galkayo) ដែលជាទីក្រុងតូចមួយរបស់ប្រទេសសូម៉ាលី។ ពេលទៅដល់ទីក្រុងនោះក្រុមចោរបានដោះដូរពួកគេជាមួយអង្គការដែលជួយសង្គ្រោះដែលអមដំណើរដោយប៉ូលិស។

លោកបានបញ្ជាក់ថា "ពួកយើងមិននឹកថា ជីវិតពួកយើងថ្ងៃអាចរស់មកជួបជុំគ្រួសារបែបនេះទេ"។

អ្នកស្រី គង់ សុភាព ជាភរិយារបស់ពលករមួយរូប ដែលជាជនរងគ្រោះម្នាក់ទៀត និយាយថាអ្នកស្រីពិតជារំភើបចិត្តមិនអាចរកអ្វីប្រៀបបានពេលដែលស្វាមីរបស់អ្នកស្រីមានជីវិតត្រឡប់មកវិញ។

អ្នកស្រីបានបន្តថា "ឲ្យតែមានជីវិតរស់នៅជួបជុំ ធ្វើស្រែ ធ្វើចំការ ក៏អាចរស់នៅបាននឹងគេដែរ"។

បន្ទាប់ពីការវិលត្រឡប់មកកាន់មាតុប្រទេសវិញ មន្ត្រីជំនាញសុខភាពផ្លូវចិត្តរបស់អង្គការការិតាស បានឲ្យដឹងថា ស្ថានភាពផ្លូវចិត្តរបស់ពលកររងគ្រោះទាំង៤នាក់ ត្រូវការពេលវេលាជួយពួកគាត់បន្ថែមទៀត ដើម្បីឲ្យពួកគាត់មានស្មារតីរឹងប៉ឹងឡើងវិញ ក្រោយពីជួបហេតុការណ៍អាក្រក់ទាំងនោះ។

លោក គឹម រតនា នាយកប្រតិបត្តិអង្គការការិតាសកម្ពុជា បានឲ្យដឹងថា អង្គការការិតាស់កម្ពុជា បានចាប់ផ្តើម សម្របសម្រួលអំពីរឿងនេះ ប្រហែលជាងមួយឆ្នាំហើយ ក្រោយពីបានទទួលដំណឹង និងសុំកិច្ចសហការពីអង្គការដៃគូ នៅក្រៅប្រទេសដែលផ្តល់ដំណឹងពីពលករខ្មែរ ត្រូវបានចាប់ជាចំណាប់ខ្មាំង នៅប្រទេសសូម៉ាលី។

លោកបានបន្តថា អង្គការការិតាស់ក៏បានស្វែងរកអត្តសញ្ញាណ និងទំនាក់ទំនងជាមួយក្រុមគ្រួសារជនរងគ្រោះ ព្រមទាំងបានជួយពួកគេរៀងមក ។

លោកបានបញ្ជាក់ថា "រហូតមកដល់ពេលនេះ និងទៅអនាគត យើងនឹងបន្តជួយគាំទ្រពួកគេផ្នែកផ្លូវចិត្ត និងគាំទ្រដល់ជីវភាពរស់នៅរបស់បងប្អូនពលករទាំង ៤ នាក់ជាបន្តទៀត ដើម្បីជួយស្តារជីវភាពរបស់ពួកគេឡើងវិញ"។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃបានថ្លែងថា នេះគ្រាន់តែជាឧទាហរណ៍ និងមេរៀនមួយជាក់ស្តែង ហើយជាសំណាងដែលពលករទាំង ៤ នាក់អាចមានជីវិតត្រឡប់មកវិញ។

លោកស្រីថា នៅមានពលករផ្សេងទៀតដែលកំពុងធ្វើការយ៉ាងលំបាកនៅក្រៅប្រទេសហើយមានអ្នកខ្លះកំពុងតែជាប់ពន្ធនាគារនៅស្រុកគេថែមទៀតផង។

រហូតមកដល់ពេលនេះ ទន្ទឹមនឹងពលករស្របច្បាប់ ដែលបានចេញទៅបម្រើការងារនៅ ប្រទេស ថៃ ម៉ាឡេស៊ី កូរ៉េខាងត្បូង ជប៉ុន ... ដោយស្របច្បាប់ កម្ពុជាក៏នៅមានបញ្ហាពលករចេញពីផ្សេងរកការងារធ្វើដោយខុសច្បាប់ នៅប្រទេសទាំងនេះ និង បណ្តាប្រទេសជាច្រើនទៀត។

ពួកគេទាំងនោះខ្លះត្រូវបានគេ កេងប្រវ័ញ្ចកម្លាំងពលកម្ម និង ហើយក៏មានអ្នកដែលត្រូវគេជួញដូរ ។

ដោយ អរិយបុត្រ

## កម្ពុជា ឡាវ និង វៀតណាមចុះកិច្ចព្រមព្រៀងសម្រួលនិងជំរុញពាណិជ្ជកម្មនៅតំបន់ត្រីកោណ

រដ្ឋមន្ត្រីបីប្រទេស កាលពីថ្ងៃទី២៣ ខែវិច្ឆិកា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួល និងជំរុញពាណិជ្ជកម្ម សម្រាប់តំបន់ត្រីកោណអភិវឌ្ឍន៍ ដែលរៀបចំនៅសណ្ឋាគារអេប្សរាផាឡេស ខេត្តសៀមរាប ក្រោមអធិបតីភាព របស់នាយករដ្ឋមន្ត្រីទាំងបី។

កិច្ចព្រមព្រៀងនេះ ត្រូវបានចុះដោយលោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា លោក សាលឹមសៃ កុំម៉ាសិទ្ធ រដ្ឋមន្ត្រីក្រសួងការបរទេសឡាវ និងង្វៀង ជីដុង រដ្ឋមន្ត្រីក្រសួងផែនការ និងវិនិយោគវៀតណាម។

ក្រសួងពាណិជ្ជកម្មបានឲ្យដឹងថា កិច្ចព្រមព្រៀងនេះត្រូវបានចុះ នៅក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់សម្តេច តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លោកថុងលូន ស៊ីសូលីត នាយករដ្ឋមន្ត្រី ឡាវ និងលោក ង្វៀង ស៊ុនហ្វុក នាយករដ្ឋមន្ត្រីវៀតណាម។

អនុលោមតាមខ្លឹមសារនៃកិច្ចព្រមព្រៀងប្រទេសកម្ពុជា ឡាវ និងវៀតណាម នឹងសហការអនុវត្តន៍ឲ្យមានលទ្ធផលល្អ ក្នុងគោលបំណងសម្រួលដល់សកម្មភាពពាណិជ្ជកម្ម និងជំរុញការវិនិយោគ នៅតាមខេត្តចំនួន ១៣ ដែលស្ថិតក្នុងតំបន់ត្រីកោណ នៃប្រទេសទាំងបី ដើម្បីធ្វើពិពិធកម្មវិស័យសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ កិច្ចព្រមព្រៀងក៏បានបញ្ជាក់ជំហររបស់ប្រទេសកម្ពុជា ឡាវ និងវៀតណាម ក្នុងការពង្រឹងកិច្ចសហការជាមួយប្រទេសសមាជិកអាស៊ានដទៃទៀត ដើម្បីសម្រេចបាននូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ ២០២៥ ផងដែរ។

## កម្ពុជានិងវៀតណាមឯកភាពគ្នាស្នើសុំអ្នកជំនាញការបច្ចេកទេសពីបារាំងលើបញ្ហាព្រំដែន

នាជំនួបទ្វេភាគីកាលពីរសៀលថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅក្រៅជំនួបកំពូលកម្ពុជា ឡាវ វៀតណាម ស្តីពីតំបន់អភិវឌ្ឍត្រីកោណ លើកទី៩ រវាងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិង សមភាគីវៀតណាម បានឯកភាពគ្នា នៅក្នុងការស្នើទៅបារាំងឲ្យផ្តល់អ្នកឯកទេសផែនទី។

លោក កៅ គឹមហួន រដ្ឋមន្ត្រីប្រតិភូនាយករដ្ឋមន្ត្រីប្រាប់ក្រុមអ្នកសារព័ត៌មានថានៅក្នុងជំនួបនេះ សម្តេចតេជោ ហ៊ុន សែន និង លោក ង្វៀន សួនហ្វ៊ុក ឯកភាពក្នុងការធ្វើលិខិតរួមគ្នាទៅកាន់ប្រទេសបារាំងដើម្បីស្នើសុំឲ្យអ្នកឯកទេសបារាំងជួយធ្វើផែនទីដែលផ្ទេរពីផែនទីពីខ្នាត១លើ ១០០.០០០ មក១លើ៥០.០០០ វិញ ហើយបានចាត់តាំងឲ្យលោក ឡុង វីសាឡូ រដ្ឋលេខាធិការក្រសួងការបរទេសនិងមានភាគីវៀតណាមដើម្បីធ្វើការរួមគ្នាទាក់ទងនឹងលិខិតផែនទីនេះ។

លោក បានបន្តថា ក្រៅពីនេះ លោកនាយករដ្ឋមន្ត្រី វៀតណាម ក៏បានស្នើរសុំសម្តេចតេជោទៅបំពេញទស្សនកិច្ចនៅប្រទេសវៀតណាមនាពេលខាងមុខ ហើយសម្តេចតេជោបានឯកភាពទៅបំពេញទស្សនកិច្ចជាផ្លូវការនៅវៀតណាមនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ខាងមុខនេះ។

## វៀតណាមដាក់ពិន័យកាសែតជាច្រើនស្ថាប័នអំពីសេចក្តីរាយការណ៍រឿងទឹកត្រី

អាជ្ញាធរវៀតណាមនៅចុងខែវិច្ឆិកា បានដាក់ពិន័យអង្គភាពសារព័ត៌មានជាច្រើនចំពោះការផ្សព្វផ្សាយសេចក្តីរាយការណ៍ព័ត៌មានមិនពិតអំពីទឹកត្រី។

ជុំវិញការដាក់ពិន័យនេះ គឺដោយសារតែកាសែតវៀតណាមផ្សាយថាទឹកត្រីមួយចំនួនដែលជាផលិតផលក្នុងស្រុកមានផ្ទុកសារជាតិពុលដ៏គ្រោះថ្នាក់ គឺសារធាតុអាសេនិក (Arsenic) ដែលបានបង្កឱ្យមានការភ័យខ្លាចនៅទូទាំងប្រទេសវៀត-ណាម ខណៈដែលទឹកត្រីត្រូវបានប្រើប្រាស់ក្នុងអាហារប្រចាំថ្ងៃនៅប្រទេស ដែលមានប្រជាជន៩៣លាននាក់នេះ។

អាជ្ញាធរវៀតណាម បានពិន័យដល់ស្ថាប័នសារព័ត៌មានចំនួន៥០ ចំពោះការ ផ្សព្វផ្សាយ ព័ត៌មាននេះ ដោយកាសែតខ្លះត្រូវបានពិន័យជាប្រាក់ជិត៩.០០០ ដុល្លារ ហើយសារព័ត៌មានផ្សេងៗទៀតត្រូវបានពិន័យចាប់ពី៤៥០ដុល្លារដល់ ២.២០០ដុល្លារ។

## រដ្ឋសភាអនុម័តហើយនៅសេចក្តីស្នើច្បាប់ថវិការមានតម្លៃ ២០.១៨៤.៤៥៧ លានរៀលសម្រាប់ឆ្នាំ២០១៧

រាជធានីភ្នំពេញៈ គម្រោងស្នើច្បាប់ថវិការជាតិឆ្នាំ២០១៧ដែលមានតម្លៃចំនួន ២០.១៨៤.៤៥៧ លានរៀល ស្មើប្រមាណ ៤.៩៥២ លានដុល្លារត្រូវបានអនុម័តរួចហើយបើទោះបីជាមានការដេញដោលពីសមាជិកគណបក្សប្រឆាំងក៏ដោយ។

សេចក្តីស្នើច្បាប់នោះ គឺផ្តល់អតិភាពលើ វិស័យ ៤ គឺអប់រំ ហេដ្ឋារចនាសម្ព័ន្ធ ការពារជាតិ និងសុខាភិបាល។

សេចក្តីព្រាងច្បាប់ថវិកាជាតិឆ្នាំ២០១៧ បានកំណត់ពីការចំណាយរបស់ក្រសួងអប់រំយុវជន និងកីឡា ចំនួន ២.៧៣៩.៩១៣ លានរៀល ស្មើប្រមាណ ៦២៧,២៩ លានដុល្លារ។ ក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ២.៤១១.០៤៨,៦ លានរៀល ស្មើប្រមាណ ៥៩១,៦ លានដុល្លារ។ ក្រសួងការពារជាតិ ត្រូវបានកំណត់ការចំណាយ ចំនួន ១.៨៥៧.១១៦,៥ លានរៀល ស្មើប្រមាណ ៤៥៥,៦៨ លានដុល្លារ។ រីឯក្រសួងសុខាភិបាល កំណត់ការចំណាយ ១.៦៩៧.៦១៤,៦ លានរៀល ស្មើប្រមាណ ៤១៦,៥៤ លានដុល្លារ។

ប្រភពដដែលបានបន្តថា ក្រសួងមហាផ្ទៃទទួលបានគម្រោងចំណាយថវិកាសរុបប្រមាណ៣៦១ដុល្លារអាមេរិក។ ក្រសួងធនធានទឹក និងឧតុនិយម ទទួលបានគម្រោងចំណាយថវិកាសរុបប្រមាណ៤៥៩លានដុល្លារអាមេរិក ហើយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវជននីតិសម្បទាទទួលបានគម្រោង ចំណាយប្រមាណ១៨៧លានដុល្លារ។

សម្រាប់ការចំណាយរបស់ថ្នាក់រដ្ឋបាលក្រោមជាតិមានថវិកាចំនួន ប្រមាណ ១៥៨លានដុល្លារ អាមេរិក ក្រៅពីនោះ មានវិស័យរដ្ឋបាលសាធារណៈ សម្រាប់បង្កើនការឧបត្ថម្ភ និងតម្លើងប្រាក់បៀវត្សរ៍មន្ត្រីរាជការ ជាដើម ។

## ព្រះមហាក្សត្រកម្ពុជាផ្ញើព្រះរាជសារលិខិតអបអរមហាក្សត្រថៃថ្មី

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២ ធ្នូ ២០១៦ បានផ្ញើរនូវព្រះរាជសារលិខិតមួយច្បាប់អបអរមហាក្សត្រថ្មីនៃព្រះរាជាណាចក្រថៃ មហាវិជ្ជ៉ាឡុងកន ។

សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះអង្គ បានសរសេរនៅក្នុងព្រះរាជសារលិខិត ថា "ក្រោយពេល ដែលព្រះអង្គមហា វិជ្ជ៉ាឡុងកន បានទទួលការយាងឲ្យគ្រងលើព្រះរាជបល្ល័ង្គ ពីសំណាកប្រធានរដ្ឋសភានៃប្រទេសថៃ ឲ្យក្លាយជាមហាក្សត្រ រាមាទី១០ នៃ ព្រះរាជវង្សចក្រីនាឱកាស ដ៏និក្ខត្តឫក្សនេះ ខ្ញុំព្រះករុណាសូមចូលរួមប្រសិទ្ធិពរ និងចូលរួមអបអរដោយភាពកក់ក្តៅបំផុត ជូនចំពោះព្រះអង្គ ហើយក៏សូមឲ្យព្រះអង្គមាន ព្រះរាជសុខភាព និងសុភមង្គលសម្រាប់សន្តិភាព និងមោទនៈភាពនៃព្រះរាជាណាចក្រ និងប្រជាពលរដ្ឋព្រះអង្គ។

ព្រះមហាក្សត្រកម្ពុជាព្រះអង្គក៏បានបញ្ជាក់ថា "ខ្ញុំព្រះករុណា មានជំនឿថា ទំនាក់ទំនងមិត្តភាពជាប្រពៃណីនិងសហប្រតិបត្តិការដែលមានស្រាប់របស់ព្រះរាជាណាចក្រទាំងពី និងពុទ្ធិសាសនិកជន នឹងបន្តរីកចម្រើនបន្តទៀតនៅក្រោម រជ្ជកាលរបស់ព្រះអង្គ"។

ព្រះអង្គ មហា វិជ្ជ៉ាឡុងកន ដែលមានព្រះជន្ម៦៤វស្សា បានក្លាយជាមហាក្សត្រថ្មីនៃប្រទេសថៃ កាលពីថ្ងៃទី០១ ធ្នូ ដោយឡើងស្នងរាជ្យពីបិតារបស់ព្រះអង្គ គឺមហាក្សត្រ ភូមិបុល អាឌុលយ៉ាដេត ដែលបានសោយទិវង្គតកាលពីថទី១៣ ខែតុលា។

ព្រះអង្គបានទទួលយកការឡើងស្នងរាជ្យនេះនៅពិធីស្នងរាជ្យដលែត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ បន្ទាប់ពីមានការយាងឡើងសោយរាជ្យពីសភា ។

# អំណរសប្បាយឬការរីករាយនៅតែជាខ្លឹមនៃបុណ្យព្រះ



ព្រឹត្តិការណ៍នៃការអបអរ និងរីករាយនាថ្ងៃទី២៥ ខែធ្នូ ថ្វីត្បិតតែមិនស្ថិតនៅក្នុងប្រតិទិនទូទៅនៅកម្ពុជា ប៉ុន្តែពលរដ្ឋទូទៅ ជាពិសេសអ្នកនៅទីប្រជុំជន បានដឹងថា ថ្ងៃនោះគឺជាថ្ងៃអ្វីបើទោះបីជា អ្នកខ្លះមិនដឹងអំពីអត្ថន័យនៃសេចក្តីពិតនៃថ្ងៃនោះក៏ដោយ។

ជុំវិញព្រឹត្តការណ៍អំណរសប្បាយនាថ្ងៃទី២៥ ខែធ្នូ នោះ លោក ហេង ចំណារ ជាប្រជាពលរដ្ឋវ័យ កណ្តាលមួយរូប បានថ្លែងថា វាសឹងតែក្លាយជាចំណែកមួយនៃសង្គមកម្ពុជានៅទីប្រជុំជនទៅហើយសម្រាប់ព្រឹត្តិការណ៍ដែលនឹងកើតមានឡើងនាថ្ងៃនោះ។

លោក ចំណារ បានឲ្យដឹងថា ថ្ងៃនោះគឺជាបុណ្យគ្រិស្តស្ម័គ្រ ដែលគេដឹងថា ជាពិធីបុណ្យរបស់ ក្រុមអ្នកមានជំនឿលើគ្រីស្តសាសនា ប៉ុន្តែព្រឹត្តិការណ៍មួយចំនួននៃពិធីបុណ្យនោះ ត្រូវបានពលរដ្ឋកម្ពុជា ជាទូទៅនៅតាមទីក្រុងចូលរួមអបអរលេងសប្បាយរីករាយជាមួយគេឯងជាបន្តបន្ទាប់។

លោកបានបញ្ជាក់ថា "ខ្ញុំមិនមែនជាគ្រីស្តបរិស័ទទេ ប៉ុន្តែគ្រួសារខ្ញុំ យើងមានកម្មវិធីរាល់តែឆ្នាំ ហើយឆ្នាំនេះ មើលទៅក៏មិនខុសពីឆ្នាំទៅដែរមើលទៅ"។

លោកស្រី សេង ហេងឈុន ជាស្ត្រីមេផ្ទះនិងជាអាជីវករមួយរូប បានចូលរួមបញ្ចេញយោបល់ថា លោកស្រីផ្ទាល់មិនដែលបានលេង បានសប្បាយនឹងគេដោយផ្ទាល់នោះទេ ប៉ុន្តែលោកស្រីបានឃើញស្វាមី និងកូនចៅលោកស្រីរីករាយរាល់ឆ្នាំ នាថ្ងៃទី២៥ ខែធ្នូនេះ ។

លោកស្រីបានបញ្ជាក់ថា "ខ្ញុំមិនដឹងនិយាយថាម៉េចទេ នៅថ្ងៃនោះ ប៉ុន្តែរាល់ឆ្នាំប្តី ខ្ញុំមានកម្មវិធីជាប់ ហើយខាងលោកកូន នាងកូននោះ ក៏ជាប់ដែរ ជួនកាលគេទៅ គេយកកូនគេទៅដែរទៅ ជួនកាលគឺយកកូនមកផ្ញើទៅក៏មាន ហើយបើអាកម្លោះៗវិញមិនដឹងជាទៅណាវាទេ គឺបាត់ៗ ពីផ្ទះ រហូតនាថ្ងៃនោះ..."។

លោកស្រីបានបន្តថា ខាងតា( ស្វាមីលោកស្រី )នោះផ្សេងទៅ ខាងកូននោះគេផ្សេងទៀតទៅ រីឯអាចៅវិញក៏ណាស់ដែរ ឃើញគេច្រើន គេរាំ ហើយថ្មីៗនេះឃើញពួកគេមកប្រាប់ថា គេចង់បានអាវគ្រីស្តស្ម័គ្រ ក៏បានទិញម្នាក់មួយសម្រាប់ពួកគេហើយដែរ ....។

លោក លឹម ណារិទ្ធ ដែលជាមន្ត្រីរាជការចូលនិវត្តន៍មួយរូប បានថ្លែងថា សម្រាប់បុណ្យគ្រីស្តស្ម័គ្រ ដែលខ្លះហៅថា បុណ្យណូអែលនោះ មិនមែនជាប្រពៃណីខ្មែរទេ។ នេះគឺជាការហូរចូលវប្បធម៌ពីលោកខាងលិច ប៉ុន្តែប្រជាពលរដ្ឋខ្មែរទូទៅបានដឹងថា ថ្ងៃទី២៥ ខែធ្នូនេះជាថ្ងៃអ្វី ។

លោកបានបញ្ជាក់ថា "បើដើរសួរថា ថ្ងៃទី២៥ ខែធ្នូជា ថ្ងៃស្អី ទាំងខ្ញុំទាំងគេអាចភាំង ប៉ុន្តែបើគេ បង្ហើបតែបន្តិចនរណាក៏ដឹងដែរ"។

លោកក៏បានបញ្ជាក់របៀបលេងសើចខ្លះៗបង្កប់បន្ថែមផងថា "មិនដឹងម៉េចបើកាលនៅធ្វើការនាថ្ងៃនោះ មានកម្មវិធីតែរហូតនឹងគេហ្នឹង ទើបតែស្ងាត់ពេលរីត្រេត ( ចូលនិវត្តន៍ ) មួយឆ្នាំពីរ ចុងក្រោយនេះ តាស់ !"។

លោកបានបន្តថា បើទោះបីជាលោក និងគ្រួសារមិនមានកម្មវិធីអ្វីក៏នៅថ្ងៃនោះ ប៉ុន្តែក៏មិនអផ្សុកដែរ នៅថ្ងៃនោះ ដោយសារតែតាមកម្មវិធីកំសាន្តតាមទូរទស្សន៍ គេមានកម្មវិធីប្លែកៗ គ្រាន់នឹងមើលលេង និងស្តាប់កំសាន្ត។

លោកបានបន្តថា បុណ្យណូអែល ឬ បុណ្យគ្រីស្តស្ម័គ្រនេះមិនមែនជាបុណ្យប្រពៃណីពីបុរមបុរាណរបស់ខ្មែរទេ ប៉ុន្តែនាសម័យនេះវាត្រូវបានបញ្ចៀបសឹងតែក្លាយជាចំណែកមួយនៃសង្គម ខ្មែរនៅតាមទីក្រុង និងតាមទីប្រជុំជនទៅហើយ។

លោកបានបន្តទៀតថា នេះគឺជាចរន្តនៃសាកលភាវូបនីយកម្ម ហើយព្រឹត្តិការណ៍ថ្ងៃនោះវាមិនមែន ត្រឹមតែសាបព្រោះតែនៅសង្គមកម្ពុជានោះទេ គឺទូទាំងសាកលលោក។

លោកបានបញ្ជាក់ថា "ទីណាក៏រីករាយដែរ នៅថ្ងៃទី២៥ ខែធ្នូ នេះ មិនថា តែនៅកម្ពុជាទេ សូម្បីតែនៅចិនដែលមានច្បាប់តឹងតែង ក៏នឹងមានការផុលផុស អធិកអធមផងដែរ ពេលណូអែលនោះ "។

លោកបានបញ្ជាក់បន្ថែមទៀតថា "ថ្ងៃនេះត្រឹមចុង ខែវិច្ឆិកាទេ ប៉ុន្តែតាមហាងទំនិញ តាមសណ្ឋាគារ តាមភោជនីយដ្ឋាន និងតាមកន្លែងផ្តល់សេវាកម្មផ្សេងៗ ចាប់ផ្តើមតែងលំអរ ហើយរៀបចំតារាង បញ្ចុះថ្លៃឬ រៀបចំកម្មវិធីឃោសនាជាបន្តបន្ទាប់បណ្តើៗហើយផងដែរ។

ទាក់ទិននឹងបញ្ហាអាជីវកម្មដើម្បីចូលរួមអបអរ និងអំណរសប្បាយជុំវិញថ្ងៃទី២៥ ខែធ្នូ ដែលគ្រីស្តបរិស័ទសន្មត់ថាជាថ្ងៃព្រះយេស៊ូប្រសូត្រនោះ លោក ហេង ចំណារ បានថ្លែងថា កូនប្រុស និងកូនប្រសាររបស់លោក ដែលជាបុគ្គលិកនៅហាងលក់អេឡិចត្រូនិចមួយ គឺកំពុងតែមមាញឹកនៅពេលនេះ។

លោកបានបន្តថា ប៉ុន្មានថ្ងៃនេះពួកគេចេញមកផ្ទះរាងយប់ ដោយសារតែ ខាងក្រុមហ៊ុនឲ្យរៀបចំ សើររើបញ្ជីស្តុកទំនិញ និងរៀបចំបញ្ចុះតម្លៃជូនអតិថិជន សម្រាប់អបអរពិធីបុណ្យនេះ។

យុវជន ជា មុន្នីរ័ត្ន បុគ្គលិកនៅហាងលក់អេឡិចត្រូនិចមួយរូប បានឲ្យដឹងថា នេះមិនមែនជាលើកទីមួយទេ ដែលក្រុម-ហ៊ុនចូលរួមអបអរ និងសាទរនូវបុណ្យណូអែលនេះ ។

មុន្នីរ័ត្ន បានបញ្ជាក់ថា "ខ្ញុំចូលបម្រើការនៅទីនេះ ៤ ទៅ៥ ឆ្នាំហើយ គឺខ្ញុំឃើញក្រុមហ៊ុនមានកម្មវិធីតែរហូតហ្នឹង"។

ប្អូនប្រុសបានបន្តថា ប្អូនមិនបានដឹងអំពីអត្ថន័យស៊ីជម្រៅនៃបុណ្យនេះទេ ប៉ុន្តែតាមការអានសៀវភៅ ស្តាប់ព័ត៌មានខ្លះ ប្អូនដឹងថា បុណ្យនេះ គឺជាបុណ្យរបស់

# ះយេស៊ូប្រសូតឬបុណ្យគ្រីស្តស្ម័គ្រនៅកម្ពុជា



ថតដោយ រិទ្ធី

គ្រីស្តសាសនា ប៉ុន្តែត្រូវគេរៀបចំ ជាសាកលទៅហើយ។

ប្អូនស្រី នុប សានិនទេវី ជាយុវសិស្សថ្នាក់វិទ្យាល័យមួយរូប បានអះអាងថា សម្រាប់ប្អូន មិត្តភក្តិ និងក្រុមគ្រួសារក៏បានត្រៀមចូលរួមរីករាយនៅថ្ងៃបុណ្យនោះផងដែរ ។

ប្អូនស្រី បានបញ្ជាក់ថា "សម្រាប់ថ្ងៃនោះខ្ញុំមិនមានអ្វីធំដុំទេ តែមានកាដូតិចតួចជូន អ្នកគ្រូ លោកគ្រូ និងមានជាកាតប៉ុស្តាល់តូចៗ ជូនមិត្តភក្តិ ហើយចូលរួមលេងសប្បាយនៅសាលាអង់គ្លេស តែប៉ុណ្ណឹង"។

សម្រាប់ឆ្នាំ២០១៧ នេះបើទោះបីជាបុណ្យនេះមិនទាន់មកដល់ ហើយពលរដ្ឋកម្ពុជាមិនទាន់បាន យល់អំពីអត្ថន័យពិតប្រាកដ ប៉ុន្តែពួកគេជាពិសេសអ្នករស់នៅទីក្រុងភ្នំពេញបានបង្ហាញពីការត្រៀមខ្លួនរួចហើយសម្រាប់អំណរសប្បាយនាថ្ងៃទី២៥ ខែធ្នូ ខាងមុខ។

យុវជន សេង សុផានិត្យ ជាយុវនិស្សិតឆ្នាំទី៤ ផ្នែកភាសាអង់គ្លេសមួយរូប បានថ្លែងថា បើតាម ការសិក្សាបុណ្យនេះមានអត្ថន័យលើសពីការសប្បាយ ។

សុផានិត្យបានបន្តថា តាមការសិក្សាស្រាវជ្រាវ គ្រីស្តស្ម័គ្រ ឬណូអែលត្រូវបានសហគមន៍អ្នក ដែលមានជំនឿលើគ្រីស្តសាសនាសន្មត់ថា ជាថ្ងៃកំណើតរបស់ព្រះយេស៊ូ ។

សុផានិត្យ បានបញ្ជាក់ថា "បើតាមខ្ញុំយល់ថ្ងៃនោះ បុណ្យនេះ ជាថ្ងៃ ព្រះយេស៊ូចុះមកចាប់កំណើតជាមនុស្ស ដើម្បីសង្គ្រោះមនុស្ស រំដោះមនុស្សចេញពីអំពើបាប"។

នេះគឺជាទស្សនៈនិងការយល់ឃើញរបស់ប្រជាពលរដ្ឋកម្ពុជាចេញពីស្រទាប់វ័យមនុស្សផ្សេងៗគ្នា ដែលបានបញ្ចេញទស្សនៈជុំវិញពិធីបុណ្យណូអែល ឬគ្រីស្តស្ម័គ្រ ឬបុណ្យព្រះយេស៊ូប្រសូតនេះ ប៉ុន្តែសម្រាប់គ្រីស្តសាសនិក បុណ្យនេះមានអត្ថន័យនិងជាបុណ្យសំខាន់មួយ។

លោក សេក ប៊ុនណា ជាគ្រីស្តបរិស័ទមួយរូបនៅក្នុងព្រះសហគមន៍កាតូលិកមានប្រសាសន៍ថា កាលពីប្លួន ទៅដប់ឆ្នាំមុន ភាគច្រើនមិនដឹងអំពីអត្ថន័យនៃបុណ្យនេះទេ ប៉ុន្តែក្រោយពេលដែលព្រះសហគមន៍កាតូលិក និងគ្រីស្តបរិស័ទរៀបចំជាបន្តបន្ទាប់ឥឡូវនេះសាធារណៈជនយល់និងដឹងអំពីអត្ថន័យនៃបុណ្យនេះច្រើន។

លោក អ៊ុន សុន បូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពខេត្តព្រះសីហនុនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍ថា ឈ្មោះនៃពិធីបុណ្យនេះគ្រាន់តែជាភាសា នៃការនិយាយ ដូចជា គ្រីស្តស្ម័គ្រ មកពីអាមេរិក ណូអែលមកពីបារាំង ហើយបុណ្យព្រះយេស៊ូប្រសូត្រជាពាក្យសម្រាយជាភាសាខ្មែរ។

លោកបានមានប្រសាសន៍បន្តថា គ្រីស្តបរិស័ទសន្មត់ថា បុណ្យនេះជាបុណ្យព្រះយេស៊ូប្រសូត្រ ដោយសារតែថ្ងៃនោះគឺជាថ្ងៃសន្មត់ថា ជាថ្ងៃដែលព្រះយេស៊ូដែលជាស្តេចនៃសេចក្តីស្រលាញ់ ការបម្រើនិងលើកលែងទោសនៅលើលោកិយដែលជាបុត្រានៃព្រះជាម្ចាស់ យាងមកចាប់កំណើតជាមនុស្ស ដើម្បីសង្គ្រោះមនុស្ស ហើយនាំមនុស្ស ទៅស្ថានបរមសុខ។

ក្នុងអំឡុងចុងខែវិច្ឆិកា ដល់ថ្ងៃទី២៥ ធ្នូ នៅតាមព្រះវិហារព្រះសហគមន៍កាតូលិក បានរៀបចំជាវិភាគទាន និងអង្គរមួយចំនួនតាមសទ្ធា និងលទ្ធភាពគ្រួសារនីមួយៗ ដើម្បីយកទៅចែកជូនគ្រួសារក្រីក្រមួយចំនួន។ នេះជាការចែករំលែកសេចក្តីស្រលាញ់ជាមួយអ្នកតូចតាច និងអ្នកក្រីក្រ។

*ដោយ អរិយបុត្រ*

## អត្ថន័យសង្ខេបនៃបុណ្យព្រះយេស៊ូប្រសូត្រ

លោក អ៊ុន សុន បូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពខេត្តព្រះសីហនុនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍ថា ការសម្រេចជ្រើសរើសថ្ងៃទី២៥ ខែធ្នូ ជាថ្ងៃប្រារព្ធពិធីបុណ្យនេះ គឺដោយសារតែ ជំនឿរបស់គ្រីស្តបរិស័ទ ។

លោកបានបញ្ជាក់ "ទោះបីក្នុងគម្ពីរគ្មានកំណត់ថ្ងៃព្រះយេស៊ូប្រសូតដ៏ដោយក៏ព្រះសហគមន៍សន្មតយកថ្ងៃទី២៥ ខែធ្នូ ធ្វើជាថ្ងៃខួបនៃកំណើតព្រះអង្គ ព្រោះនៅផ្នែកខាងជើងនៃផែនដីចាប់ពីថ្ងៃទី២៥ ធ្នូទៅ ថ្ងៃកាន់តែមានរយៈពេលវែងបន្តិចម្តងៗ។ អ្នកស្រុកនៅមជ្ឈិមបូព៌ា និងអឺរ៉ុបពីដើមយកថ្ងៃនោះធ្វើបុណ្យយ៉ាងឱឡារិកខាងសាសនារបស់ពួកគេដើម្បីគោរពព្រះអាទិត្យដែលបំភ្លឺខ្លីទៅៗ ដូចស្លាប់ថារស់ឡើងវិញពីថ្ងៃនោះ។ គ្រីស្តបរិស័ទក៏លើកថ្ងៃនោះមកគោរពព្រះគ្រីស្តទុកជាពន្លឺនៃពិភពលោក ដូចជាថ្ងៃរះឡើងដែរ "។

លោកបានបន្តថា ពន្លឺសំខាន់ណាស់សម្រាប់គ្រីស្តបរិស័ទ ហើយដោយថ្ងៃនោះពន្លឺវែង ទើបបុព្វបុរសនៃគ្រីស្តបរិស័ទសន្មត់យកថ្ងៃនោះ។ លោកបានបន្តទៀតថា ទម្រាំ ដល់ថ្ងៃនេះ ចាប់ពីថ្ងៃទី២៧ ខែវិច្ឆិកាមក គ្រីស្តបរិស័ទ ចាប់ផ្តើមអបអរ និងសាទរបុណ្យនេះហើយ ដោយហៅអំឡុងពេលនេះ រហូតដល់ថ្ងៃទី២៥ ខែធ្នូ ថា ជារដូវរង់ចាំ។

លោកបានបន្តទៀតថា នៅក្នុងរយៈពេល ៤សប្តាហ៍នេះ ជាអំឡុងពេលដែលគ្រីស្តបរិស័ទអប់រំចិត្តគំនិត ដើម្បីត្រៀមទទួលព្រះយេស៊ូ។

## សកម្មភាពគ្រីស្តបរិស័ទដែលធ្វើ និងគ្រោងចូលរួមអំណរសប្បាយបុណ្យព្រះយេស៊ូប្រសូត្រ

លោក សេក ប៊ុនណា ជាគ្រីស្តបរិស័ទមួយរូបនៅក្នុងព្រះសហគមន៍កាតូលិក បានមានប្រសាសន៍ថា នៅក្នុងអំឡុងពេល៤ អាទិត្យនៃរដូវរង់ចាំនេះគឺជាពេលដែលគ្រីស្តបរិស័ទ ត្រូវរំឭក និងអប់រំចិត្តគំនិតឡើងវិញ តាមបន្ទូលរបស់ព្រះជាម្ចាស់។

លោកបានមានប្រសាសន៍បន្តទៀតថា តាមពិតទៅនៅក្នុងនាមជាគ្រីស្តបរិស័ទគឺត្រូវប្រកាន់វិន័យ និងប្រតិបត្តិខ្លួនតាមព្រះបន្ទូលតាំងពីយើងស្គាល់ព្រះជាម្ចាស់ និងពិធីទទួលអគ្គសញ្ញាជ្រមុជទឹកមកម្ល៉េះ ប៉ុន្តែអំឡុងពេលនេះ ជាពេលយើងរិះគិតឡើងវិញ ដោយការអធិដ្ឋាន ការចូលរួមធ្វើសកម្មភាពមនុស្សធម៌ និងសកម្មភាពផ្សេងៗតាមគំរូរបស់ព្រះជាម្ចាស់។

លោកបានបន្តទៀតថា សកម្មភាពរបស់គ្រីស្តបរិស័ទសម្រាប់ចូលរួមអបអរអំណរសប្បាយនៃ ពិធីបុណ្យនេះ គឺធ្វើទៅតាមជំនឿ និងទៅតាមលទ្ធភាពរបស់យើងម្នាក់ៗ។

លោកបានបញ្ជាក់ថា "ដូចជាគ្រួសារខ្ញុំ គឺយើងអាចមានការចំណាយបន្តិចបន្តួចជួបជុំគ្នា សាច់ញាតិបងប្អូន និងខ្លះទៀតសម្រាប់ទិញជាដង្វាយយកទៅព្រះវិហារសម្រាប់ចែកជូនបងប្អូនទីទាល់ក្រជាដើម"។

លោកបានបន្តថា នៅគេហដ្ឋាន គឺយើងមានការរៀបចំសំអាត តុបតែង រូបសំណាកព្រះនាងម៉ារី និងព្រះយេស៊ូ ដាក់ភ្លើងដាក់អំពូលសរុបទៅមួយឆ្នាំ អាចអស់៣០០ ទៅ៤០០ដុល្លារដែរ។

# អ្នកគង្វាលថ្មី ជាក្ដីសង្ឃឹមថ្មីរបស់ព្រះសហគមន៍



ថតដោយ សុធីរិទ្ធ

សម្លេងភ្លេងប្រគុំឡើង កុមារតូចៗចាប់ផ្ដើមពត់ពេនតាមចង្វាក់ភ្លេងនៃរបាំក្ងោក ដែលមានសម្លៀកបំពាក់ពណ៌បៃតងចាស់ ដើរលើកម្រាលព្រំពណ៌ក្រហមដែលក្រាលទុកជាស្រេច អមដោយគ្រីស្ដបរិស័ទជាងមួយពាន់នាក់បានឈរអមសងខាងផ្លូវ។ របាំក្ងោកបានធ្វើដំណើរនាំមុខ ក្បួនដង្ហែដែលមានឈើឆ្កាងព្រះយេស៊ូ លោកឧបដ្ឋាក និងឪពុកម្ដាយ លោកបូជាចារ្យ និងលោកអភិបាលព្រះសហគមន៍កាតូលិក ដែលមកពីបីភូមិភាគប្រកបដោយអំណរសប្បាយ ហាក់ដូចជាក្បួនជ័យរបស់កូនកម្លោះចូលក្នុងពិធីមង្គលការ។

ក្បួនដង្ហែត្រូវបានបញ្ចប់នៅមុខអាសនៈ ដែលរៀបចំបានយ៉ាងស្អាត តុបតែដោយផ្កាភ្ញី និងផ្ទាំងគំនូរ និងមានសរសេរអក្សរថា អ្នកគង្វាលដ៏ល្អតែងតែស៊ូប្ដូរជីវិតដើម្បីចៀមរបស់ខ្លួន។ មួយសន្ទុះក្រោយមក លោកអភិបាលព្រះសហគមន៍បានត្រាស់ហៅជាឱឡារិកឲ្យលោកឧបដ្ឋាក ស្ទេផាន សែ សាតមកឈរនៅមុខអាសនៈ។ លោកស្ទួរបញ្ជាក់ពីចេតនានៃការថ្វាយខ្លួនដល់ព្រះជាម្ចាស់ក្នុងនាមជាអ្នកគង្វាលហ្វូងចៀមរបស់ព្រះអង្គដែលមានមុខងារជាបូជាចារ្យ។ លោកឧបដ្ឋាក ស្ទេផាន សែ សាតបានក្រាបមុខដល់ដី ហើយលោកអភិបាល និងបូជាចារ្យនានាបានលុតជង្គង់រួមជាមួយសន្តបុគ្គលទាំងឡាយឯស្ថានបរមសុខ អង្វរព្រះជាម្ចាស់សូមព្រះអង្គប្រទានព្រះពរ និងផ្ដល់កម្លាំងដល់លោកបូជាចារ្យថ្មីរូបនេះ។

ក្រោយពីលោកអភិបាលបានធ្វើពិធីត្រៀបដៃ លាបប្រេង និងប្រគល់គ្រឿងសក្ការៈបូជាជូនដល់លោកបូជាចារ្យថ្មីរួច លោកស្ទេផាន សែ សាតត្រូវបានបំពាក់អាវមេអំបៅ និងទទួលស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់បូជាចារ្យ និងលោកអភិបាលនៅចំពោះមុខព្រះសហគមន៍។ នេះជាអគ្គសញ្ញាតែងតាំងជាបូជាចារ្យតាមរបៀបព្រះសហគមន៍កាតូលិក ដែលបានធ្វើឡើងកាលពីថ្ងៃទី១៩ វិច្ឆិកា ២០១៦ នៅព្រះសហគមន៍កាតូលិកកំពង់ចាមក្រុងក្នុងខេត្តកំពង់ចាម។

ក្នុងសម្លៀកបំពាក់ជាបូជាចារ្យ លោកបូជាចារ្យស្ទេផាន សែ សាត មានប្រសាសន៍ថា ក្នុងនាមជាបូជាចារ្យថ្មី ព្រះយេស៊ូគ្រីស្ដគឺជាគំរូដ៏សំខាន់សម្រាប់គាត់ ហើយដោយសារគំរូនេះ នាំឲ្យជីវិតរបស់គាត់ចង់ក្លាយជាបូជាចារ្យ។ លោកបូជាចារ្យបញ្ជាក់ថា "អ្វីដែលខ្ញុំត្រូវប្រកាសជាអ្វីដែលព្រះយេស៊ូបានធ្វើ គឺព្រះបន្ទូលរបស់ព្រះអង្គ សេចក្ដីស្រឡាញ់របស់ព្រះអង្គ"។

លោកបូជាចារ្យវ័យ៣៥ឆ្នាំ រូបនេះ បន្តថា ក្នុងមុខងារជាបូជាចារ្យ លោកត្រូវមើលថែមនុស្សលោក បំពេញកិច្ចការដោយសេចក្ដីស្រឡាញ់ និងហ៊ានបូជាជីវិតដូចព្រះយេស៊ូ។ ជាបូជាចារ្យ លោកត្រូវស្ដាប់សម្លេងរបស់ព្រះយេស៊ូ ធ្វើតាមការណែនាំរបស់លោកអភិបាល និងតាមការណែនាំរបស់បងប្អូនគ្រីស្ដបរិស័ទដែលរស់នៅជាមួយ ដើម្បីអាចបំពេញកិច្ចការតាមព្រះហឫទ័យព្រះអង្គ។ លោកស្ទេផាន សែ សាត បញ្ជាក់ "ខ្ញុំគិតថា កិច្ចការដែលខ្ញុំធ្វើ គឺត្រូវរួមជាមួយព្រះដើម្បីឲ្យកិច្ចការនោះក្លាយជាវិសុទ្ធ។ ទោះបីខ្ញុំជាបូជាចារ្យ ខ្ញុំក៏ត្រូវការការអធិដ្ឋានពីបងប្អូន ការអប់រំ និងការណែនាំ។ ខ្ញុំនៅតែជឿថា ខ្ញុំជាអ្នកបាបដែលព្រះជាម្ចាស់ត្រាស់ហៅដើម្បីជួយអ្នកបាបផ្សេងទៀតតាមរយៈអគ្គសញ្ញាអភិបូជានិងអគ្គសញ្ញាសម្រុះសម្រួល"។

លោកឧបដ្ឋាក ស្ទេផាន សែ សាត មានស្រុកកំណើតនៅក្នុងភូមិខ្ទប់ដំរីត្បូង ឃុំដំរិល ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ មកពីព្រះសហគមន៍កាតូលិកចម្លាក់ ក្នុងភូមិភាគកំពង់ចាម។ លោកជាកូនប្រុសច្បងក្នុងចំណោមគ្រួសារជាពុទ្ធបរិស័ទ និងជាកសិករដែលមានប្អូនស្រី៤នាក់ និងប្រុសម្នាក់។

លោកនួន សែ ជាឪពុករបស់បូជាចារ្យសាតបានមានប្រសាសន៍ថា "ខ្ញុំមានចិត្តអបអរដែលកូនក្លាយជាបូជាចារ្យ។ សូមឲ្យកូនចេះបម្រើព្រះសហគមន៍នេះឲ្យបានរីកចម្រើនទៅអនាគត រហូតអស់មួយជីវិត"។

លោកបូជាចារ្យស្ទេផាន សែ សាត បានក្លាយជាគ្រីស្ដបរិស័ទក្នុងឆ្នាំ២០០៥ ហើយលោកបានស្នើសុំលោកអភិបាលព្រះសហគមន៍ដើម្បីចូលក្នុងទេវវិទ្យាល័យក្នុងឆ្នាំ២០០៨។ក្នុងឆ្នាំ២០១៤លោកត្រូវបានលោកអភិបាលប្រគល់មុខងាជាអ្នកបម្រើតុសក្ការៈនៅព្រះសហគមន៍ប៊ូស្រា ខេត្តមណ្ឌលគិរី រហូតដល់ឆ្នាំ២០១៥ទើបលាកទទួលការតងែតាំងជាឧបដ្ឋាកនៅព្រះសហគមន៍អ្នកលឿងក្នុងខេត្តព្រៃវែង។ បន្ទាប់ពីទទួលមុខងារជាឧបដ្ឋាក លោកត្រូវបានលោកអភិបាលភូមិភាគកំពង់ចាមចាត់ឲ្យទៅបម្រើនៅព្រះសហគមន៍កាតូលិកអ្នកលឿងចំនួន៤ខែបន្ទាប់មកទៅបម្រើនៅព្រះសហគមន៍ក្ដុលលើខេត្តត្បូងឃ្មុំចំនួន៣ខែមុនពេលតែងតាំងជាបូជាចារ្យ។

លោក អន់តូនីសាមី ស៊ូសៃរាជ្យ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមមានប្រសាសន៍ថា លោកបូជាចារ្យថ្មី ជាមនុស្សដែលមានចិត្តក្លាហាន ចេះស្ដាប់បង្គាប់និងមានចិត្តសុភាពរាបសារ។ លោកអភិបាលបន្តទៀតថា នេះគឺមកពីគំរូឪពុកម្ដាយរបស់គាត់ដែលមានចិត្តសប្បុរស ដែលធ្វើឲ្យមករតនេះមកដល់បូជាចារ្យសែ សាត ហើយវាជាកម្លាំងសម្រាប់គាត់ដែរ។ លោកអភិបាលបន្ថែមថា គ្រីស្ដបរិស័ទទាំងចាស់ក្មេង ចូលចិត្តលោកសាត ព្រោះគាត់ជាមនុស្សសាមញ្ញ។ លោកអភិបាលបន្តថា "សូមឲ្យគ្រីស្ដបរិស័ទចេះផ្ដល់កម្លាំងចិត្តឲ្យសាតតាមរបៀបសាមញ្ញទាំងនេះ"។

ក្នុងមុខងារជាបូជាចារ្យ លោកស្ទេផាន សែ សាត ត្រូវបានលោកអភិបាលអន់តូនីសាមី ចាត់ឲ្យទៅបម្រើការងារក្នុងតំបន់កំពង់ចាមជាមួយលាកបូជាចារ្យអ៊ីវ៉ាន់ កំប៉ាញ៉ា។

លោកអេនរីគេ ហ្វីការេដូ ជាអភិបាលព្រះសហគមន៍កាតូលិកមានប្រសាសន៍ថា "ខ្ញុំមានអំណរសប្បាយ ដែលមានបូជាចារ្យជាជនជាតិខ្មែរថ្វាយជីវិតសម្រាប់ព្រះជាម្ចាស់ ព្រះសហគមន៍ និងអ្នកក្រីក្រ មានន័យថាព្រះសហគមន៍ប្រទេសកម្ពុជារីកចម្រើន។ ខ្ញុំគិតថា មានសារៈសំខាន់សម្រាប់ក្រុមយុវជន ជាពិសេសសម្រាប់ព្រះសហគមន៍ទាំងមូល គឺឲ្យយើងចេះយកពេលវេលាដើម្បីអធិដ្ឋាននៅជិតស្និទ្ធជាមួយព្រះជាម្ចាស់ បម្រើអ្នកតូចតាច សួរសុខទុក្ខបងប្អូន យកចិត្តទុកដាក់ជាមួយក្មេងកំព្រាដែលជាបុត្រធីតារបស់ព្រះជាម្ចាស់"។

លោកអភិបាលមានប្រសាសន៍ទៀតថា យុវជនត្រូវយកចិត្តទុកដាក់ចូលរួមក្នុងសកម្មភាពព្រះសហគមន៍ ជួយអ្នកក្រីក្រ បម្រើអ្នកក្រីក្រ។ លោកអភិបាល "ពេលណាយើងរៀនព្រះគម្ពីរ អំពីព្រះសហគមន៍ប្រវត្តិសាស្ត្រ យើងអាចទៅខាងមុខបាន។ ខ្ញុំមានសង្ឃឹមច្រើន ដោយសារយើងមានយុវជនល្អបំផុត ដូច្នេះយើងត្រូវប្រមូលកម្លាំងដើម្បីយើងអាចទៅខាងមុខបាន។

លោក អូលីវីយេ ឝ្មីតអីស្លែរ អភិបាលជាអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញមានប្រសាសន៍ថា ការសិក្សាដើម្បីក្លាយជាបូជាចារ្យត្រូវការពេលវេលាយូរឆ្នាំដើម្បីណែនាំ អប់រំឲ្យស្គាល់ជីវិតជាអ្នកបួស។ ជាបូជាចារ្យ ជីវិតលែងជាលក្ខណៈឯកជនទៀតហើយ។ លោកអភិបាលអូលីវីយេ "ខ្ញុំអរព្រះគុណព្រះជាម្ចាស់សម្រាប់ថ្ងៃនេះ និងសូមព្រះអង្គប្រទានពរដល់សាតថែមទៀត និងជាពិសេសខ្ញុំសូមព្រះសហគមន៍យើងទាំងអស់ជួយអធិដ្ឋានឲ្យគាត់ ដោយសារនេះជាជីវិតថ្មីដែលទើបចាប់ផ្ដើម និងគាត់ត្រូវការមានកម្លាំង ត្រូវការមានសេចក្ដីស្រឡាញ់ដ៏ពេញលេញ។ ហើយនេះក៏បានមកពីព្រះសហគមន៍ដែរដែលអធិដ្ឋាន និងគាំទ្រគាត់ជានិច្ច ដូច្នេះឲ្យគាត់ធ្វើដំណើរនៅក្នុងសេចក្ដីសុខរួមជាមួយព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា ជាពិសេសព្រះសហគមន៍ភូមិភាគកំពង់ចាម"។

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ លោកបូជាចារ្យជាតិខ្មែរមានចំនួន៩នាក់ ដែលកំពុងបម្រើការងារក្នុងព្រះសហគមន៍កាតូលិកនៅក្នុងបីភូមិភាគ។ ចំនួននេះមានតិចតួចណាស់បើប្រៀបធៀបនឹងតម្រូវការបច្ចុប្បន្នរបស់ព្រះសហគមន៍កាតូលិក ដែលមានប្រមាណជាង៨០ព្រះសហគមន៍ និងមានគ្រីស្ដបរិស័ទកាតូលិកជាង២ម៉ឺននាក់នៅលើផ្ទៃប្រទេស ដែលកំពុងត្រូវការអ្នកគង្វាលជាបូជាចារ្យដើម្បីណែនាំនិងអប់រំផ្លូវវិញ្ញាណ។

ព្រះសហគមន៍កាតូលិកកម្ពុជាត្រូវបានបំផ្លាញទាំងស្រុងដោយរបបប៉ុលពត។ បព្វជិត បព្វជិតា អ្នកបួស និងលោកអភិបាលជាតិខ្មែរត្រូវបានសម្លាប់ និងស្លាប់ដោយអត់អាហារនិងជំងឺ។ សព្វថ្ងៃនេះ ព្រះសហគមន៍រស់ឡើងវិញ ដោយមួយផ្នែកធំត្រូវពឹងលើសាសនទូតពីក្រៅប្រទេសនានាដើម្បីគាំទ្រ។

# ខួប ៧០ឆ្នាំ នៃការបង្កើតក្រុមគ្រួសារពន្លឺមិត្តភាព

ក្រុមគ្រួសារពន្លឺមិត្តភាព បានប្រារព្ធខួប ៧០ឆ្នាំ នៃបង្កើតគ្រួសារនេះ ក្រោមអធិបតីភាពលោកអូលីវីយេ ជ្មីតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ កម្មវិធីនេះធ្វើឡើងនាល្ងាចថ្ងៃទី០៤ ខែធ្នូ ២០១៦ ដោយមានការចូលរួមពីសំណាក់កម្មការិនី និងភ្ញៀវជាច្រើននាក់ នៅក្នុងបរិវេណផ្ទះរបស់ក្រុមគ្រួសារនេះនៅ បឹងទំពុន រាជធានីភ្នំពេញ។

លោកអភិបាលអូលីវីយេ បានបំផុសឲ្យអ្នកចូលរួមចាប់អារម្មណ៍អំពីផ្ទាំងរូបភាពនៃស្ថាបនិកក្រុមគ្រួសារពន្លឺមិត្តភាព ដែលរៀបជារូបផ្ទះ។ លោកបញ្ជាក់ថា ផ្ទះជាកន្លែងដែលគ្រួសារស្នាក់នៅ ជាកន្លែងជួបជុំគ្នា ហើយគ្រួសារពន្លឺមិត្តភាពជាកន្លែងដែលជួបជុំគ្នាយ៉ាងកក់ក្តៅ និងទោះបីជាយើងមកពីកន្លែងខុសៗគ្នាតែជាគ្រួសារដែលចេះស្រឡាញ់គ្នា។

លោកអូលីវីយេ បានលើកឡើងទៀតថា គ្រួសារជាច្រើនខ្វះសេចក្តីសុខ ហើយដើម្បីបង្កើតគ្រួសារសុខសាន្តលុះត្រាតែកូនខិតខំរៀនសូត្រ យកចិត្តទុកដាក់ស្តាប់ឪពុកម្តាយ យកចិត្តទុកដាក់បង្កើតទំនាក់ទំនងជាមួយមិត្តភក្តិ។ លោកបន្តទៅមាតាបិតាថា ត្រូវយកពេលវេលាដើម្បីមើលថែកូន យកចិត្តទុកដាក់ស្វាគមន៍ និងផ្តល់សេចក្តីស្រឡាញ់ដល់បងប្អូនឯទៀតៗ។

តាមការរៀបរាប់របស់កញ្ញាឆ្មារ យូប្រាកដ ដែលជាសមាជិកជនជាតិខ្មែរដំបូងក្នុងក្រុមគ្រួសារពន្លឺមិត្តភាពបានឲ្យដឹងអំពីប្រវត្តិនៃក្រុមគ្រួសារនេះថា ក្រុមនេះបានកកើតឡើងដោយសារ លោកយាយតេរេសា ហ្វាកនីស ដែលបានធ្វើការនៅរោងចក្រ ហើយបានយល់អំពីទុក្ខលំបាករបស់ជនក្រីក្រ។

ដោយមានគាំទ្រពីព្រះសហគមន៍កាតូលិក ក្រុមគ្រួសារនេះបានបង្កើតឡើងក្នុងឆ្នាំ១៩៤៦ នៅតំបន់ភាគខាងជើងនៃប្រទេសបារាំង។ ក្នុងឆ្នាំ១៩៦២ បានបង្កើតនៅអាហ្វ្រិក និងបានបង្កើតនៅក្នុងប្រទេសផ្សេងៗជាបន្តបន្ទាប់។ ក្នុងឆ្នាំ ១៩៦៧ លោកអភិបាល អ៊ីវ រ៉ាម៉ូស ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញនៅពេលនោះ បានស្នើសុំឲ្យបង្កើតក្រុមគ្រួសារពន្លឺមិត្តភាពនៅប្រទេសកម្ពុជា។ ក្នុងឆ្នាំ១៩៧៣ ក្រុមនេះមានទីតាំងនៅតំបន់ជ្រោយចង្វារ ហើយត្រូវបង្ខំឲ្យបិទទ្វារវិញក្នុងឆ្នាំ១៩៧៥ ក្នុងសម័យខ្មែរក្រហម។ ក្រោយមកគ្រួសារនេះបានបើកទ្វារឡើងវិញក្នុងឆ្នាំ១៩៩៩។



ថតដោយ សុធីរិទ្ធ

ក្រុមគ្រួសារពន្លឺមិត្តភាពជាគ្រហស្ថដែលបែងចែកជាពីរផ្នែកគឺ អ្នកសច្ចានៅលីវអស់មួយជីវិត និងជាគ្រហស្ថធម្មតាអាចមានក្រុមគ្រួសារបាន។ ក្រុមនេះទទួលសមាជិកជាស្ត្រីទាំងគ្រីស្តបរិស័ទ និងបរិស័ទនៃសាសនាណាក៏បាន ឲ្យតែអាចសម្របខ្លួនរស់នៅក្នុងក្រុមគ្រួសារពន្លឺមិត្តភាព ដោយទទួលយកនូវរបៀបរស់នៅដែលសាកសមជាស្ត្រីថ្លៃថ្នូរ និងជាគំរូសម្រាប់អ្នកដទៃ។

សព្វថ្ងៃក្រុមគ្រួសារនេះមានវត្តមាននៅក្នុងប្រទេសចំនួន១៨ ដែលមានបេសកកម្មសំខាន់ គឺយកចិត្តទុកដាក់ជួយកម្មករកម្មការិនី ជួយក្រុមគ្រួសារក្រីក្រ និងស្ត្រីមានវិបត្តិ ជាពិសេសយកចិត្តទុកដាក់ចំពោះការសិក្សារបស់កុមារ រួមទាំងផ្តល់នូវសេវាសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដើម្បីធានាឲ្យបាននូវសេចក្តីសុខសាន្ត និងភាពកក់ក្តៅនៅក្នុងក្រុមគ្រួសារ។

*ដោយ ដាលីស*

# ខួប ១៥ឆ្នាំនៃការតែងតាំងបូជាចារ្យជាតិកម្ពុជាទាំង ៤រូប



ថតដោយ សម្បត្តិ

ពិធីអរគុណចំពោះខួប ១៥ឆ្នាំនៃអគ្គសញ្ញាតែងតាំងជាបូជាចារ្យ របស់លោកបូជាចារ្យខ្មែរទាំង៤រូបមានលោក អ៊ុន សុន លោក ប៉ូល ឡាយ លោកសួន ហង្សលី និងលោកង៉ែត វិន័យ។ ពិធីនេះប្រារព្ធនៅព្រះវិហារសន្តប៉ូល និងសន្តសិលាភ្នំពេញថ្មី ក្រោមអធិបតីភាព លោកអភិបាលអូលីវីយេ ជ្មីតអីស្លែរ កាលពីល្ងាចថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០១៦។ ក្នុងធម្មទេសនា លោកអភិបាលអូលីវីយេ បានរំឭក អំពីតួនាទីជាបូជាចារ្យគឺ៖ ១) ធ្វើជាសហការីនៃលោកអភិបាលក្នុងការប្រកាសដំណឹងល្អដល់មនុស្សគ្រប់ជាតិសាសន៍។ ២) ប្រារព្ធអគ្គសញ្ញានានា។ និង៣) អធិដ្ឋានទូលអង្វរព្រះជាម្ចាស់សម្រាប់មនុស្សលោកទាំងមូល។ លោកអភិបាលក៏បានរំលឹកឲ្យលោកបូជាចារ្យទាំងអស់មានចិត្តមេត្តាករុណា អាណិតអាសូរ ហើយលោកបន្ថែមថា កម្លាំងរបស់យើងក្នុងការបំពេញកិច្ចការទាំងនោះ គឺបានមកពីព្រះជាម្ចាស់ផ្ទាល់។ នៅក្នុងអភិបូជាខួប១៥ ឆ្នាំនេះលោកបូជាចារ្យទាំង៤រូប បានប្រកាសពាក្យសច្ចារបស់ខ្លួនសារជាថ្មីនៅចំពោះមុខលោកអភិបាល និងព្រះសហគមន៍ គឺស្ម័គ្រចិត្ត រួមស្លាប់រួមរស់ជាមួយព្រះយេស៊ូ ជាព្រះអម្ចាស់អស់ពីចិត្ត ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួន និងប្រកាសដំណឹងល្អយ៉ាងស្មោះត្រង់ព្រមទាំងបំពេញកិច្ចការរបស់ព្រះជាម្ចាស់ដោយយកគំរូតាមព្រះយេស៊ូជាគង្វាល។ លោកអភិបាលអូលីវីយេ បានប្រទានពរដោយទូលអង្វរព្រះជាម្ចាស់សម្រាប់លោកទាំងបួនរូបនេះ ដើម្បីបំពេញ និងបម្រើយកិច្ចការរបស់ព្រះអង្គ។ លោកអភិបាលបន្តថា ការថ្វាយដង្វាយ គឺថ្វាយជីវិតបូជាចារ្យដោយ នឹកឃើញដល់មនុស្សដែលអស់សង្ឃឹម និងថ្វាយកិច្ចការទាំងអស់ទៅព្រះជាម្ចាស់។ លោកបូជាចារ្យទាំងនោះបានផ្តល់សក្ខីភាពរបស់ខ្លួននៅក្នុងជីវិតត្រាស់ហៅជាបូជាចារ្យ។ ក្នុងនោះលោកបូជាចារ្យ សួន ហង្សលី បានមានប្រសាសន៍អំពីការត្រាស់ហៅនេះថា "ខ្ញុំជាយុវជនម្នាក់ក្នុងគ្រួសារធម្មតា ជាអ្នកនេសាទត្រីជាកសិករ តែព្រះជាម្ចាស់បានជ្រើសរើសកែច្នៃឲ្យធ្វើជាបូជាចារ្យ និងជួយណែនាំបងប្អូនឲ្យស្គាល់ព្រះជាម្ចាស់"។ លោកថាព្រះជាម្ចាស់បានកែច្នៃខ្ញុំដែលជាដុំថ្មធម្មតានេះឲ្យទៅជាដុំថ្មសំខាន់"។ ដោយឡែកលោកបូជាចារ្យ អ៊ុន សុន បានមានប្រសាសន៍ថា "ជីវិតនៃការត្រាស់ហៅរបស់ខ្ញុំ គឺគ្រួសារហើយសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់មហាគ្រួសារដ៏ធំនេះ"។ លោក បន្តថានៅពេលដែលមានទុក្ខលំបាក និងហត់នឿយ បើយើងតែម្នាក់ឯងនឹងពិបាក តែពេលយើងរួមគ្នា និងចែករំលែកជាមួយគ្នា នោះនាំឲ្យយើងបាត់អស់ទុក្ខលំបាកទាំងនោះ។ លោកបូជាចារ្យទាំង៤បានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យក្នុងឆ្នាំ២០០១។ អស់លោកជាបូជាចារ្យបានទទួលអគ្គសញ្ញាតែងតាំងជំនាន់ទី២បន្ទាប់ពីសង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជាបានបញ្ចប់។ ព្រះសហគមន៍នៅកម្ពុជាបានទទួលរងនូវការបំផ្លាញស្ទើរទាំងស្រុងក្នុងរបបខ្មែរក្រហមប៉ុលពត។ លោកអភិបាលអស់លោកបូជាចារ្យ បព្វជិត បព្វជិតា និងគ្រីស្តបរិស័ទ មួយចំនួនធំត្រូវខ្មែរក្រហមសម្លាប់ និងស្លាប់ដោយអត់ឃ្លាន។ អាគារព្រះវិហារ។ ស្ទើរតែទាំងអស់បានបំផ្លាញចោល។ ព្រះសហគមន៍បានរស់ឡើងវិញក្នុងទស្សវត្សឆ្នាំ១៩៩០។ រហូតដល់សព្វថ្ងៃយើងមានបូជាចារ្យជាតិខ្មែរចំនួន៩នាក់។

*ដោយ ដាលីស*

# បុណ្យគោរពព្រះនាងម៉ារី គ្មានជំពាក់បាបនិងការអធិដ្ឋានសម្រាប់ការត្រាស់ហៅ លើកទី៥៥


ថតដោយ សម្បត្តិ

នៅរសៀលថ្ងៃទី០៨ ធ្នូ ២០១៦ នេះ ព្រះសហគមន៍នៅក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើង នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំបុណ្យគោរពព្រះនាងម៉ារីគ្មានជំពាក់បាប និងការអធិដ្ឋានសម្រាប់ការត្រាស់ហៅលើកទី៥៥ នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច ក្រោមអធិបតីភាពលោកអូលីវីយេ ជ្មីតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួមជាមួយលោកបូជាចារ្យ បងប្រុស បងស្រី និងមានការអញ្ជើញចូលរួមពីក្រុមគ្រីស្តបរិស័ទនៃព្រះសហគមន៍នានា ក្នុងមណ្ឌលសកម្មភាពភ្នំពេញខាងជើងយ៉ាងច្រើនកុះករ។

មានប្រសាសន៍ក្នុងធម្មទេសនាឱកាសនោះ លោកអភិបាលអូលីវីយេ បានលើកឡើងថា ក្នុងឱកាសរំឭកអំពីព្រះនាងម៉ារីគ្មានជំពាក់បាបនេះ គឺជាពេលវេលាមួយយ៉ាងពិសេស ដែលណែនាំយើងឲ្យចូលទៅក្នុងអាថ៌កំបាំងរបស់ព្រះជាម្ចាស់ គឺអាថ៌កំបាំងនៃធម៌មេត្តាករុណារបស់ព្រះអង្គ ។ នៅថ្ងៃនេះ ព្រះនាងម៉ារី បាននាំឲ្យយើងចាប់អារម្មណ៍អំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងបាននាំឲ្យយើងចូលទៅក្នុងអំណរសប្បាយ។ នៅក្នុងជីវិតរបស់យើងម្នាក់ៗ ជាគ្រីស្តបរិស័ទ ក្រៅតែពីគិតអំពីអំណរសប្បាយ យើងតែងតែសម្លឹងមើលអំពីទុក្ខលំបាកក្នុងជីវិតរបស់ខ្លួនផងដែរ ដោយព្រះជាម្ចាស់បានជួយណែនាំយើងឲ្យចេះស៊ូទ្រាំ និងជំនះនូវការលំបាកទាំងនោះ និងបានប្រទានព្រមទាំងជ្រើសរើសយើង ដោយសារព្រះអង្គមានព្រះហឫទ័យស្រឡាញ់ ហើយព្រះអង្គបានចាត់ទុកយើងជាមនុស្សពិសេស និងឲ្យយើងក្លាយទៅជាបុត្រធីតារបស់ព្រះអង្គទៀតផង ។

លោកអភិបាលបានបន្តថា ប្រសិនបើយើងយកព្រះនាងម៉ារីជាគំរូ សម្រាប់ជីវិតរបស់យើង គឺយើងត្រូវកែប្រែចិត្តគំនិតដោយចេះឆ្លើយតបតាមការត្រាស់ហៅរបស់ព្រះអង្គ ដូចព្រះនាងម៉ារីដែរ។ តាមពិតគម្រោងការណ៍របស់ព្រះជាម្ចាស់សម្រាប់យើងម្នាក់ៗ គឺជួយយើងឲ្យទៅជាមនុស្សវិសុទ្ធ ឥតសៅហ្មង ដោយសារព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់យើង នេះជាការអស្ចារ្យនៃជីវិតរបស់យើង។

ទាក់ទងទៅនិងក្រុមគ្រួសារ លោកអភិបាលបានមានប្រសាសន៍ដោយសង្កត់ធ្ងន់ថា នេះឱកាសមួយសម្រាប់បងប្អូនជាគ្រីស្តបរិស័ទ ដែលមានក្រុមគ្រួសារហើយ គឺសូមយកគំរូរបស់ព្រះនាងម៉ារីដោយធ្វើជាគំនូរ ដើម្បីគិតថា យើងជាប្ដីប្រពន្ធ ជាឪពុកម្ដាយ ជាតាយាយ ជាក្រុមគ្រួសារ យើងត្រូវធ្វើយ៉ាងម៉េច ដើម្បីជាគំរូនៅក្នុងជីវិតខ្លួនជាគ្រីស្តបរិស័ទ ដែលស្រឡាញ់ព្រះយេស៊ូ សម្រាប់កូនចៅរបស់ខ្លួន ដោយធ្វើយ៉ាងណា ដើម្បីឲ្យព្រះសហគមន៍យើងទៅជាព្រះសហគមន៍សម្រាប់ព្រះគ្រីស្ត ព្រះសហគមន៍របស់ព្រះគ្រីស្ត គឺជាព្រះសហគមន៍ដែលបំរើ គឺបំរើអ្នកដែលតូចតាចជាងគេ។

សូមបញ្ជាក់ថា នៅក្នុងកម្មវិធីបុណ្យគោរពព្រះនាងម៉ារី គ្មានជំពាក់បាបនេះផងដែរ ក៏បន្តជាមួយពិធីតាំង និងគោរពព្រះកាយព្រះគ្រីស្ត និងការអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅលើកទី៥៥។ នេះជាការអធិដ្ឋានទូលអង្វរទៅព្រះជាម្ចាស់សូមព្រះអង្គជួយបំភ្លឺចិត្តគំនិតយុវជន យុវនារី ឲ្យចេះឆ្លើយតបតាមការត្រាស់ហៅរបស់ព្រះយេស៊ូ ក្នុងការបំពេញកិច្ចការបម្រើព្រះជាម្ចាស់ និងបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជា។

គួររំឭកថា នៅឆ្នាំ១៤៣៩ ក្នុងមហាសន្និបាតក្រុងបាសិល ប្រទេសស្វីស បានចាត់ទុកថា ព្រះនាងម៉ារី គ្មានជំពាក់បាប គឺជំនឿមួយ ដែលគ្រីស្តបរិស័ទត្រូវជឿ។ ហើយនៅឆ្នាំ១៨៥៤ សម្ដេចប៉ាប ពីយ៉ូ ទី៩ ទ្រង់ប្រកាសជាគោលលទ្ធិជំនឿមួយរបស់គ្រីស្តបរិស័ទ៕

*ដោយ ឡុង សម្ផស្ស*

# អ្នកក្រីក្រ៥០០គ្រួសារបានទទួលអំណោយពីក្រុមបងស្រីមេត្តាករុណា

អ្នកក្រីក្រ៥០០គ្រួសារ បានទទួលអំណោយ ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត ពីក្រុមគ្រួសារបងស្រីមេត្តាករុណា ក្រោមអធិបតីភាពរបស់លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ អូលីវីយេ ជ្មីតអីស្លែរ។ពិធីនេះប្រព្រឹត្តទៅកាលពីថ្ងៃទី១៧ ធ្នូ ២០១៦កន្លងទៅ នៅគ្រឹះស្ថានមេត្តាករុណាផ្លូវមុន្នីវង្ស។

ជារៀងរាល់ឆ្នាំ ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត ក្រុមបងស្រីមេត្តាករុណា តែងប្រមូលបងប្អូន ដែលក្រីក្រ បងប្អូនអាណាថា អ្នកសុំទានតាមផ្លូវ មកជួបជុំគ្នាចែកអំណរសប្បាយ និងអំណោយផ្សេងៗដល់ពួកគេ។


ថតដោយ សុធីរិទ្ធ

នៅក្នុងឱកាសដ៏សប្បាយរីករាយនេះ លោកអភិបាលអូលីវីយេ ក៏បានលើកទឹកចិត្តដល់អ្នកដែលមកទទួលអំណោយទាំងនោះថា ថ្ងៃនេះយើងមានអំណរសប្បាយ ដោយដឹងថារដូវបុណ្យព្រះយេស៊ូប្រសូតបានមកដល់ហើយ។

លោកបន្តថា ចំពោះយើងជាគ្រីស្តបរិស័ទមានន័យថា រដូវនេះជាពេលដែលយើងចែករំលែក សេចក្ដីសុខ សេចក្ដីសង្ឃឹម កម្លាំងកាយកម្លាំងចិត្ត និងអំណរសប្បាយជាមួយបងប្អូនទាំងអស់។

លោកថា ថ្ងៃនេះដែរជាកម្មវិធីមួយដែលមានលក្ខណៈអន្តរសាសនាម្យ៉ាង ជាគ្រួសារតែមួយនៅក្នុងសេចក្ដីសង្ឃឹម។ បងប្អូនមានទុក្ខលំបាកច្រើន តែថ្ងៃនេះសូមឲ្យយើងយល់ថា យើងជាបងប្អូនគ្នា និងយល់ចិត្តគ្នាទៅវិញទៅមក។ លោកក៏បានលើកទឹកចិត្តបងប្អូន ក្នុងការកសាងគ្រួសារ ឲ្យទៅជាគ្រួសារសុខសាន្ត ដោយចេះសហការណ៍ជួយគ្នា និងគោរពគ្នាទៅវិញទៅមក។ សូមឪពុកម្ដាយកុំចោលកូន ហើយចិញ្ចឹមកូនដោយក្ដីស្រឡាញ់ ឲ្យកូនបានទៅសាលា ជាពិសេសសូមឲ្យយើងចេះតស៊ូ ព្រោះជីវិតគឺជាការតស៊ូដើម្បីឲ្យកូន និងគ្រួសារមានអនាគតល្អ។

បងប្អូនដែលមកទទួលអំណោយទាំងនោះ មកពីកោះនរាហ៍ ច្បារអំពៅ ចាក់អង្រែ ស្ទឹងមានជ័យ និងអ្នកដែលនៅជុំវិញខ័ណ្ឌដូនពេញ។ អំណោយទាំងនោះមានដូចជា អង្ករ គ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ។

ក្រុមបងស្រីមេត្តាករុណា បង្កើតឡើងដោយសន្តី តេរេសា នៃក្រុងកុលកូថា ប្រទេសឥណ្ឌា ហើយបានមកបំពេញបេសកកម្មនៅកម្ពុជា ក្នុងទសវត្ស១៩៩០ ដោយបម្រើអ្នកជំងឺធ្ងន់ធ្ងរគ្មានទីពឹង កុមារកំព្រា កុមារគេបោះបង់ចោល ជនពិការ និងចាសជរាជាដើម។ នៅប្រទេសកម្ពុជា ក្រុមនេះមាននៅ ភ្នំពេញ២កន្លែង និងមួយកន្លែងនៅខេត្ត សៀមរាប។

*ដោយ ដាលីស*

# លោកបូជាចារ្យ ប៊ែរណា ឈឹម ឈុនសារ( ១៩៣៩-១៩៧៥ )



## Père Bernard ChimChunsar, osb

## បូជាចារ្យបព្វជិត ក្រុមអ្នកបួសបេណេឌិកតាំង

លោកប៊ែរណា ឈឹម ឈុនសារមានស្រុកកំណើតនៅបាត់ដំបង ជាជនជាតិខ្មែរ។ លោកកើតនៅឆ្នាំ ១៩៣៩។ រៀនសូត្រនៅបាត់ដំបង ក្រោយមកចូលរៀនបួសនៅផ្សារតូច ដែលបានហៅអនុទេវវិទ្យាល័យ( ផ្សារតូច )នៅភ្នំពេញ។ ក្រោយមកមានចំណាប់អារម្មណ៍នៅខាងអ្នកបួស ក្រុមបព្វជិតបេណេឌិកតាំង។ បន្ទាប់មកលោកមកនៅក្រុងកែបក្នុងអារាមអ្នកបួស បេណេឌិកតាំងនោះទីនោះ។

លោកមានចិត្តសប្បុរស ជួយដឹកនាំធ្វើការងារក្នុងវត្តអារាម។ គាត់ដឹកនាំអ្នករៀបចំបួស នៅក្នុងអារាម អប់រំវិន័យរបស់ក្រុមសម្រាប់ពួកគេ។ ទទួលខុសត្រូវខាងកសិកម្ម ជួយចិញ្ចឹមជីវិតក្នុងអារាម។ គាត់មិនគិតប្រយោជន៍ផ្ទាល់ខ្លួនគឺ ធ្វើដើម្បីព្រះជាម្ចាស់។ ទោះបីគាត់មកពីក្រុមគ្រួសារធូរធារដែរ។ ប៉ុន្តែគាត់លះបង់ដើម្បីព្រះជាម្ចាស់។ គាត់ធ្លាប់ឆ្លើយតបគ្រីស្តបរិស័ទម្នាក់ថា "ខ្ញុំចូលចិត្តធ្វើជាអ្នកបួស"។

របៀបការនិយាយ មានរបៀបបែបមនុស្សចេះដឹង។ លោកមានទំនាក់ទំនងរហូតដល់ចៅហ្វាយខេត្ត ដោយសារលោកជាខ្មែរ។ លោកទទួលការតែងតាំងជាបូជាចារ្យនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៦៥។ លោកមានតួនាទីថ្វាយអភិបូជាសម្រាប់បងប្រុស។ លោកជាបូជាចារ្យខ្មែរដំបូង របស់ក្រុមគ្រួសារបព្វជិតនេះ។

ចាប់ពីឆ្នាំ១៩៧០ ទៅក្រុងកែបត្រូវមានសង្គ្រាមខ្លាំងរវាងវៀតកុងច្បាំងជាមួយនឹងកម្ពុជាសាធារណរដ្ឋ។ ពេលនោះ លោករំឭកយើងថា "យើងមិនដឹងទៅណាទៀតទេ មានតែសង្ឃឹមទៅលើព្រះជាម្ចាស់ និងអធិដ្ឋានតែប៉ុណ្ណឹង"។

ក្រោយមកឆ្នាំ ១៩៧៣ ខ្មែរក្រហមយកក្រុងកែបបាន។ លោកដឹកនាំបព្វជិត២-៣ រូបទៀត និងគ្រួសារកាតូលិកខ្លះទៅភ្នំពេញ។ លោកជួយទំនាក់ទំនង រហូតបានឡានមកដល់ភ្នំពេញ។ លោកដឹកនាំនវកជនកាតូលិករបស់វត្តអារាម គឺលោកដានីសេងនិមិត្ត និងអង់ ជ្រេ រដ្ឋរំដួរ។ ពេលលោកទាំងបីមកដល់ភ្នំពេញ លោកទៅរស់នៅក្នុងទេវវិទ្យាល័យធំ នៅជ្រោយចង្វារ។ នៅពេលនោះក្រុមរបស់លោកមានឈ្មោះល្បី ព្រោះលោកបានជួយអ្នកក្រីក្រ។

ពេលភ្នំពេញបែក ខ្មែរក្រហមជម្លៀសលោក និងនវកជនពីរអង្គទៀត រួមជាមួយលោកសាឡាស់ លោកសាឡឹម និងលោកសំរើនទៅភូមិតាំងគោក ជាមួយគ្រីស្តបរិស័ទដែលមកពីភូមិព្រះមាតា។ លោកនឹងនវកជន ២ នាក់ព្រមទាំងយុវជន ៤នាក់ ស្នាក់នៅក្នុងខ្ទមតូចមួយ នៅភូមិសំរៀង ដែលនៅពេលនោះលោកបានជួបគ្រីស្តបរិស័ទហើយលបណាត់គ្នា ដើម្បីថ្វាយអភិបូជាដោយសម្ងាត់ថ្វាយការអត់ឃ្លានទៅព្រះបិតា។

លោកប៊ែរណា ត្រូវប្តូរទីលំនៅទៅនៅភូមិអូរពុះនៅជិតភូមិអណ្តូងដា។ លោកអភិបាល សាឡាស, លោកសាឡឹម, លោកសំរើន ជួបជុំគ្នានៅផ្ទះលោកប៊ែរណាដើម្បីថ្វាយអភិបូជា។ ឪពុករបស់លោកសាឡឹមបានយកត្រឡោកដូង ធ្វើជាពែងកាលិក្ស។ ចំណែកពែងដាក់ព្រះកាយព្រះគ្រីស្ត លោកដាក់ក្នុងពែងដែលបងស្រីរបស់លោករំដួរឲ្យ។ នៅពេលលោកបូជាចារ្យទាំងបួនថ្វាយអភិបូជា ពួកយុវនារីធ្វើដូចជាបេះស្លឹកឈើឬរកអុសជិតផ្ទះ ដើម្បីឃ្លាំកងឈ្លបនិងអ្នកប្លែកមុខចូល។

ប្រហែល ខែកញ្ញា ឆ្នាំ១៩៧៥ ក្រោយមកដោយសារអត់ឃ្លានពេក លោកប៊ែរណា លោករំដួរ និងលោកនិមិត្ត ទៅថ្វាយអភិបូជាចុងក្រោយនៅតាំងគោកជាមួយលោកសាឡាស់ សាឡឹម និងលោកសំរើន។ ក្រោយអភិបូជា ពួកគេញ៉ាំបាយជាមួយគ្នាទាំងទឹកមុខស្ងួតក្រៀមក្រំ។ លោកប៊ែរណា ព្រួយបារម្ភអំពីការធ្វើដំណើររបស់លោក លោកនិយាយថា "យើងត្រូវបែកផ្លូវគ្នាស្វែងរកកូនចៀម យើងមិនអាចនៅផ្តុំគ្នាមួយកន្លែងដូច្នេះទេ..."។

ក្រោយមក លោកទាំងបីត្រូវខ្មែរក្រហមចាប់ហើយសម្លាប់នៅតាមផ្លូវត្រង់ភូមិសាលាវិលៃប្រហែលនៅខែកញ្ញា ឆ្នាំ ១៩៧៥ ។

---



សន្ត: យ៉ូហាន ម៉ារីវិយ៉ាណែ

លោកយ៉ូហាន ម៉ារី កើតនៅប្រទេសបារាំង នៅឆ្នាំ១៧៨៦។ កាលគាត់នៅក្មេង គាត់ធ្វើការនៅក្នុងកសិដ្ឋានរបស់ឪពុកគាត់។ នៅពេលគាត់ត្រឡប់មកពីការងារវិញ គាត់បង្រៀនក្មេងៗឲ្យចេះអធិដ្ឋាន និងឲ្យគេស្គាល់ព្រះយេស៊ូ។ លោកយ៉ូហាន ម៉ារី រៀនមិនសូវពូកែ តែមានលោកបូជាចារ្យម្នាក់ជួយឲ្យគាត់ចូលទៅរៀននៅក្នុងទេវវិទ្យាល័យ។ យូរឆ្នាំក្រោយមក ក្រោយពីបានខិតខំរៀនអស់ពីសមត្ថភាព លោកយ៉ូហាន ម៉ារី ក្លាយទៅជាបូជាចារ្យ។ គេបញ្ជូនគាត់ទៅក្នុងព្រះសហគមន៍ដ៏តូចមួយ នៅភូមិអាស។ ដោយ សារគ្មាននរណាម្នាក់ទៅព្រះវិហារទេ លោកឪពុកយ៉ូហាន ម៉ារី ទៅសួរសុខទុក្ខគេនៅតាមផ្ទះ។ ជាចុងក្រោយ មនុស្សជាច្រើនបានទៅព្រះវិហារចូលរួមអភិបូជា។ ជារៀង រាល់ព្រឹក គាត់តាំងព្រះកាយ និងអធិដ្ឋានជាច្រើនម៉ោង។ គាត់រស់នៅដូចជាអ្នកក្រីក្របំផុត និងតមអាហារជាញឹកញាប់។ ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រោសប្រទានព្រះអំណោយទានដ៏ពិសេសដល់គាត់ គឺគាត់ពូកែសម្រុះសម្រួលមនុស្សបាប ជាមួយព្រះជាម្ចាស់ និងជួយទូន្មានពួកគេឲ្យទៅធ្វើជាគ្រីស្តបរិស័ទដ៏ល្អ។ គាត់ចំណាយពេលអស់ជាច្រើន ដោយធ្វើអគ្គសញ្ញាលើកលែងទោស។ គាត់ធ្លាប់និយាយថា៖ រាល់អំពើបាបរបស់យើង ដូចជាតំណក់ទឹកនៅក្នុងមហាសមុទ្រនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ លោកឪពុកយ៉ូហាន ម៉ារី ជួយណែនាំព្រះសហគមន៍នៅភូមិអាស អស់រយៈពេល ៤០ឆ្នាំហើយ ទទួលមរណភាពនៅពេលអាយុ៧៣ឆ្នាំ។ គាត់ជាគំរូសម្រាប់លោកបូជាចារ្យទាំងអស់។

# ខួប៤ឆ្នាំនៃការស្រង់ព្រះនាងម៉ារីពីបាតទន្លេមេគង្គ



ថតដោយ សុធីរិទ្ធ

ព្រះសហគមន៍កាតូលិកកម្ពុជា បានរៀបចំពិធីបុណ្យរំឭកខួប៤ឆ្នាំនៃការរកឃើញរូបសំណាកព្រះនាងម៉ារីនៅបាតទន្លេមេគង្គ ក្នុងភូមិអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល។ ពិធីនេះបានចាប់ផ្ដើមដោយអធិដ្ឋានសូត្រផ្គុំ និងប្រារព្ធពិធីបុណ្យអរព្រះគុណព្រះជាម្ចាស់យ៉ាងឱឡារិក កាលពីថ្ងៃទី២០ វិច្ឆិកា ២០១៦ ក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ ឆ្មឹត អឺស្លែរ និងមានគ្រីស្តបរិស័ទប្រមាណជា ១៥០០នាក់។

ក្នុងធម្មទេសនា លោកអភិបាលបានមានប្រសាសន៍ថា ថ្ងៃនេះព្រះសហគមន៍ណែនាំឲ្យយើងសម្លឹងមើលព្រះនាងម៉ារី និងព្រះយេស៊ូ ដែលជាឱកាសឲ្យយើងរិះគិត និងដឹងថាព្រះជាម្ចាស់បានណែនាំឲ្យយើងចេះដាក់ខ្លួនតាមរបៀបព្រះនាងម៉ារី តាមរយៈការរស់នៅក្នុងសង្គម ព្រោះយើងជឿថាព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក ជាពិសេសអ្នកតូចតាច។

លោកបន្តថា នៅគ្រប់ទីកន្លែងដែលព្រះនាងម៉ារីបង្ហាញខ្លួន បានណែនាំមនុស្សឲ្យ កែប្រែចិត្តគំនិត លើកលែងទោសឲ្យគ្នាទៅវិញទៅមក និងផ្ដល់សក្ខីភាពឲ្យពិភពលោកជាពិភពថ្មីនៃក្ដីសុខសាន្ត។

លោកអភិបាល អូលីវីយេ ក៏បានទទូចឲ្យគ្រីស្តបរិស័ទ ធ្វើតាមព្រះនាងម៉ារី ដោយផ្ដល់សក្ខីភាពអំពីព្រះជាម្ចាស់ និងធ្វើដោយសកម្ម។ លោកបន្តថា "យើងមិនត្រឹមតែជាគ្រីស្តបរិស័ទស្ងើរៗទេ តែយើងរួមជាមួយព្រះនាងម៉ារី ដើម្បីអនុវត្ត និងបង្ហាញឲ្យពិភពលោកទទួលជីវិតថ្មី"។

លើសពីនេះទៅទៀត លោកបានស្នើឲ្យគ្រីស្តបរិស័ទមកទីនេះមិនត្រឹមតែសុំព្រះពរពីព្រះនាងម៉ារីទេ តែសូមស្ដាប់ព្រះនាងម៉ារីដែលសុំឲ្យយើងកែប្រែទៅជាមនុស្សថ្មី ដើម្បីឲ្យចេះសម្រុះសម្រួលគ្នាទៅជាមហាគ្រួសារតែមួយនៅក្នុងពិភពលោកនេះ។

លោកបន្ថែមថា ព្រះនាងម៉ារីបានស្នើសុំយើងឲ្យក្រោកឡើងធ្វើជាគ្រីស្តទូត និងជាសាវ័កព្រះគ្រីស្ត។ ត្រៀមជានិច្ចដោយឆ្លើយតបទៅនឹងព្រះគ្រីស្ត ដោយធ្វើជាអ្នកបម្រើ និងលីឈើឆ្កាងជាមួយព្រះយេស៊ូ។ លោកបន្តថា យើងត្រូវធ្វើជាគ្រីស្តបរិស័ទសកម្មកែប្រែចិត្តគំនិតនិងធ្វើជាសាក្សីនៃការលើកលែងទោសរបស់ព្រះជាម្ចាស់។

ក្នុងឱកាសដ៏ឱឡារិកនេះ លោកអភិបាលប្រកាសសម្រាប់ឆ្នាំ២០១៧ខាងមុខ គឺនៅទីនេះនឹងមានការអធិដ្ឋានសូត្រផ្គុំ អប់រំ និងអភិបូជាដើម្បីបន្តទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូតាមរយៈព្រះនាងម៉ារី ជារៀងរាល់ថ្ងៃសៅរ៍ក្នុងសប្ដាហ៍ទី៤ ។

លោកអាជ្រីយ៉ាន បេនីតេស ហ្វូស្តាវ៉ូ ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍អរិយក្សត្រនេះបានមានប្រសាសន៍ថា "ចាប់តាំងពីទទួលបានព្រះនាងម៉ារីដែលស្រង់ចេញពីទឹកនោះមក ព្រះសហគមន៍នៅទីនេះមានភាពរីកចម្រើនជាងមុនច្រើនណាស់ ដោយមានគ្រីស្តបរិស័ទទាំងក្នុង និងក្រៅប្រទេសមកទីនេះ ដើម្បីអធិដ្ឋាន និងមានពេលខ្លះមានទាំងព្រះសង្ឃនៃព្រះពុទ្ធសាសនាមហាយាន ព្រមទាំងបងប្អូនដែលមិនមែនជាគ្រីស្តបរិស័ទមកសូត្រធម៌ផងដែរ"។ លោកបញ្ជាក់ទៀតថា ចំពោះជំនឿរបស់បងប្អូនគ្រីស្តបរិស័ទនៅទីនេះវិញ ក៏មានការប្រែប្រួលខុសពីមុនដោយចាប់ផ្ដើមយកចិត្តទុកដាក់ និងមកព្រះវិហារទៀងទាត់ទៀតផង។

រូបសំណាកព្រះនាងម៉ារីដែលព្រះសហគមន៍ប្រារព្ធខួប៤ឆ្នាំនេះ គឺជារូបសំណាកទីពីរដែលព្រះសហគមន៍អរិយក្សត្រទទួលបានពី លោក សុខ ហ៊ូ ដែលបានស្រង់ចេញពីបាតទន្លេមេគង្គ កាលពីថ្ងៃទី១៩ វិច្ឆិកា ២០១២។ ក្រោយពីស្រង់ព្រះនាងម៉ារីមក គាត់បានកែប្រែចិត្តគំនិតជឿលើព្រះយេស៊ូ និងទទួលអគ្គសញ្ញាជ្រមុជទឹកកាលពីឆ្នាំ២០១៥កន្លងមកនេះ។

*ដោយដាលីស*

# សាសនាធំៗទាំងបី រិះគិតអំពីការទប់ស្កាត់អំពើហិង្សាលើកុមារនៅកម្ពុជា



ថតដោយ លី សុវណ្ណា

សិក្ខាសាលា ស្ដីពីការប្រារព្ធទិវាសកម្មភាពសាសនាដើម្បីកុមារ និងតួនាទីរបស់មេដឹកនាំសាសនាក្នុងកិច្ចការពារកុមារនៅកម្ពុជា បានបើកជាផ្លូវការក្រោមអធិបតីភាពឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ។

លោករដ្ឋមន្ត្រីបានផ្ដល់យោបល់ដល់សិក្ខាកាមទាំងអស់ថា សូមមេត្តាយកព្រះធម៌វិន័យសាសនានានាដើម្បីផ្សព្វផ្សាយអំពីសីលធម៌ គុណធម៌ ការការពារនៅតាមវត្តអារាម វិហារ ស្នាក់ការ សាលារៀន ឬគ្រប់សហគមន៍ដែលនៅជិតបំផុត។

សូមមេត្តា យកចិត្តទុកដាក់ខ្ពស់ ក្នុងការទប់ស្កាត់អំពើហិង្សាលើកុមារ រួមចំណែកពង្រឹងសុខដុមនីយកម្មក្នុងសង្គមស្របតាមច្បាប់រដ្ឋធម្មនុញ្ញរបស់ជាតិ។ ប្រឹងប្រែងពង្រឹងនិងពង្រីកការអប់រំតាមរយៈព្រះធម៌វិន័យ ទ្រឹស្ដីរបស់សាសនា ដើម្បីអភិវឌ្ឍធនធានមនុស្ស រួមចំណែកដល់ការអភិវឌ្ឍជាតិ។

សិក្ខាសាលាប្រព្រឹត្តទៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ នៅសាលប្រជុំសាលាខេត្តកណ្ដាល ដែលមានសិក្ខាកាមយ៉ាងច្រើនកុះករ មកពីគ្រប់សាសនាធំៗទាំងបីនៅកម្ពុជា។

*ដោយ លី សុវណ្ណា*

# កិច្ចប្រជុំបូកសរុបវាយតម្លៃសកម្មភាពការងាររបស់សមាគមសិស្សចាស់ដុនបូស្កូកម្ពុជា



ថតដោយ សុធីរិទ្ធ

សមាគមសិស្សចាស់ដុនបូស្កូកម្ពុជា កាលពីព្រឹកថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦ នេះបានជួបជុំគ្នានៅក្នុងពិធីជួបប្រជុំសិស្សចាស់ដុនបូស្កូគ្រប់ជំនាន់ លើប្រធានបទ **"សិស្សចាស់ និងការអភិវឌ្ឍន៍" ដោយមាន** ការចូលរួមជាអធិបតីពីសំណាក់លោកបូជាចារ្យរ៉ូអែល សូតូ និងលោកបូជាចារ្យផ្សេងៗទៀត ព្រមទាំងមានការចូលរួមពីគណៈគ្រប់គ្រងសមាគមសិស្សចាស់រួមនិងអតីតសិស្សដុនបូស្កូចាប់ពីជំនាន់ទី១ រហូតដល់ជំនាន់ទី២៤ នាឆ្នាំ២០១៦នេះ។

ថ្លែងនៅក្នុងពិធីនោះលោកបូជាចារ្យរ៉ូអែល សូតូ ជាប្រធានសម្របសម្រួលកម្មវិធីសាលាដុនបូស្កូ ភ្នំពេញថ្មី បានមានប្រសាសន៍ទាក់ទងទៅ និងសកម្មភាព និងសារប្រយោជន៍នៃការទំនាក់ទំនងរវាងសាលា និងសមាគម ដោយលោកគូសបញ្ជាក់ថា យើងឃើញហើយថា យើងមានសមាគមសិស្សចាស់ ដែលមាននៅក្នុងក្រុមគ្រួសាររបស់លោកឪពុកដុនបូស្កូ ដើម្បីចែកបទពិសោធន៍នូវការសិក្សារបស់យើងដែលបានទទួលនៅសាលាជាមួយក្រុមគ្រួសាររបស់យើង អ្នកជិតខាងរបស់យើង និងក្នុងសង្គមរបស់យើងផងដែរ។

លោកបូជាចារ្យរូបនេះបានបន្ថែមទៀតថា លោកឪពុកបូស្កូតែងតែបង្កើតឲ្យមានសមាគមសិស្សចាស់នៅក្នុងសាលា គឺដើម្បីជួយឲ្យសិស្សចាស់របស់យើង បានចែករំលែកនូវបទពិសោធន៍របស់ខ្លួនជាមួយអ្នកផ្សេងៗទៀត និងចែករំលែកបទពិសោធន៍ដែលខ្លួនមានទៅដល់សង្គមរបស់ខ្លួននោះផង។ យើងម្នាក់ៗជាអតីតសិស្សសាលាដុនបូស្កូ ដែលបានទទួលនូវការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ការកសាងអនាគតរបស់ខ្លួន ត្រូវបន្តនូវបេសកកម្មរបស់លោកឪពុកបូស្កូ នៅក្នុងការជួយដល់កូនចៅរបស់យើង ជាពិសេសជួយដល់ប្រជាពលរដ្ឋខ្មែរ និងសិស្សដុនបូស្កូជំនាន់ក្រោយ ឲ្យពួកគេមានអនាគតល្អដូចជាពួកយើងដែរ។

លោកជៀម សុវណ្ណារិទ្ធ ប្រធានសមាគមសិស្សចាស់ដុនបូស្កូកម្ពុជាអណត្តិទី៣ បានឲ្យដឹងថា នៅថ្ងៃនេះ គឺជាថ្ងៃដែលយើងបានជួបគ្នាជាថ្មីម្តងទៀត នៅក្រោយពេលដែលយើងខកខានមិនបានជួបគ្នាអស់រយៈពេលជាងមួយឆ្នាំកន្លងទៅ ក្រោយពេលបោះឆ្នោតជ្រើសរើសប្រធានសមាគមអណត្តិទី៣។ ក្នុងរយៈពេលមួយឆ្នាំកន្លងផុតទៅហើយ យើងឃើញថា សកម្មភាពរបស់សមាគមមួយចំនួន ក៏មិនបានអនុវត្តទៅតាមផែនការ ដូចដែលយើងបានគ្រោងទុក។ ប៉ុន្តែយើងខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីឲ្យដំណើរសកម្មភាពរបស់សមាគមយើងអាចបន្តដំណើរទៅមុខ។

លោកបានបន្តថា៖ នៅថ្ងៃនេះយើងជួបជុំគ្នា ដើម្បីផ្លាស់ប្តូរបទពិសោធន៍គ្នា និងបានឮអំពីចំណាប់អារម្មណ៍ផ្សេងៗរបស់អតីតសិស្សចាស់ទៅលើការងាររបស់សិស្សរបស់យើង នូវអ្វីដែលជាបញ្ហា ក៏ដូចជាបទពិសោធន៍សម្រាប់សិស្សជំនាន់ៗក្រោយ ដែលបានរៀនចប់ពីសាលាទៅ។ ការជួបជុំគ្នានាពេលនេះ គឺជាជួយរំលឹកយើងនូវអនុស្សាវរីយ៍ចាស់ៗ និងការជួបជុំជាមួយមិត្តភក្តិចាស់ទាំងអស់ ដែលធ្លាប់បានរៀនជាមួយគ្នាក្នុងពេលកន្លងទៅ ។

លោកជៀម ចាន់ថុល ជាអតីតសិស្សដុនបូស្កូជំនាន់ទី៤ បានលើកឡើងថា ការសិក្សានៅសាលាដុនបូស្កូនេះ គឺជួយយើងមិនត្រឹមតែការផ្តល់នូវជំនាញវិជ្ជាជីវៈប៉ុណ្ណោះទេ ប៉ុន្តែបានអប់រំយើងទាំងផ្នែកសីលធម៌ និងបំណិតជីវិតផ្សេងៗទៀត សម្រាប់ជាការត្រួសត្រាយផ្លូវជីវិតរបស់យើងទៅថ្ងៃអនាគត។ ជាមួយគ្នានេះលោកចាន់ថុលបានលើកទឹកចិត្តឲ្យដល់សិស្សដុនបូស្កូទាំងអស់ទាំងចាស់ ទាំងសិស្សថ្មី គប្បីពង្រឹងត្រូវសមត្ថភាពរបស់ខ្លួននៅក្នុងការប្រើប្រាស់ភាសាអង់គ្លេសផងដែរ គឺយើងឃើញហើយថា នៅក្នុងសង្គមកម្ពុជាយើងនាពេលសព្វថ្ងៃនេះ ការប្រើប្រាស់ភាសាបរទេស ជាពិសេសភាសាអង់គ្លេសជាជំហានមួយទៀតជួយយើងឲ្យមានការអភិវឌ្ឍន៍ខ្លួនមួយកម្រិតទៀត។

គួររំឭកថាសមាគមសិស្សចាស់ដុនបូស្កូកម្ពុជា ចាប់ដំណើរការតាំងពីឆ្នាំ២០១០ កន្លងទៅ ដោយមានការផ្តួចផ្តើមគំនិតពីក្រុមសិស្សចាស់មួយចំនួនក្នុងការជួយសម្របសម្រួល ប្រមូលព័ត៌មានអំពីសិស្សចាស់ទាំងអស់ និងមានគម្រោងការផ្សេងៗដើម្បីជួយគាំទ្រ និងឧបត្ថម្ភព្រមទាំងស្វែងរកព័ត៌មានការងារនានានៅតាមក្រុមហ៊ុនដែលជាដៃគូរបស់សាលា ដើម្បីផ្តល់ឲ្យសិស្សចាស់មួយចំនួនដែលមិនទាន់មានការងារធ្វើជាដើម ។ *ដោយ ឡុង សម្ផស្ស*

**ព័ត៌មានសង្គម**

# កម្ពុជាក្លាយជាប្រធានគណៈកម្មាធិការនៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤

រាជធានីភ្នំពេញៈ កម្ពុជាកាលពីពេលថ្មីៗនេះ ត្រូវបានជ្រើសរើសជាឯកច្ឆ័ន្ទឲ្យធ្វើជាប្រធានគណៈកម្មាធិការនៃអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ របស់អង្គការយូណេស្កូ ស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ។

យោងទៅតាមសារមួយដែលធ្វើឡើងដោយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការអបអរការជ្រើសរើសនេះ បានបញ្ជាក់ថា បេក្ខភាពរបស់កម្ពុជា ត្រូវបានគេគាំទ្រនៅក្នុងកិច្ចប្រជុំលើកទី១១នៃគណៈកម្មាធិការនេះ ដែលរៀបចំឡើងនៅក្នុងកិច្ចប្រជុំលើកទី១១ នៅទីស្នាក់ការរបស់អង្គការយូណេស្កូ នាទីក្រុងប៉ារីស ពីថ្ងៃទី០៨ ដល់ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ ។

នៅក្នុងសារនោះសម្តេចតេជោ ហ៊ុនសែន បានសរសេរថា ភាពជាប្រធានរបស់កម្ពុជានេះ គឺជាជោគជ័យថ្មីមួយទៀតនៃគោលនយោបាយអភិរក្ស និងលើកតម្លៃបេតិកភ័ណ្ឌវប្បធម៌របស់មនុស្សជាតិ ដែលត្រូវបានលើកស្ទួយ និងអនុវត្តយ៉ាងសកម្មដោយរាជរដ្ឋាភិបាលកម្ពុជា នឹងបង្ហាញយ៉ាងច្បាស់ផងដែរនូវតួនាទីកាន់តែសំខាន់ និងឈានមុខរបស់កម្ពុជានៅលើឆាកអន្តរជាតិ ជាពិសេស គឺនៅក្នុងវិស័យបេតិកភ័ណ្ឌ និងវប្បធម៌សម្រាប់មនុស្សជាតិ។

គិតត្រឹមថ្ងៃទី១៣ តុលា ២០១៦ គណៈកម្មាធិការនេះ មានប្រទេសចំនួន ១២៧ ជារដ្ឋភាគីនៃអនុសញ្ញានេះ នៅក្នុងនោះប្រទេសជារដ្ឋភាគីនៃពិធីសារទី១ ឆ្នាំ១៩៥៤ មាន ១០៤ ប្រទេស និង មានប្រទេសចំនួន ៦៩ ទៀត បានចូលជារដ្ឋភាគីនៃពិធីសារទី២ ដែលជាក្របខណ្ឌគតិយុទ្ធដ៏មានសារៈសំខាន់ ដោយបានបង្កើតឲ្យមានគណៈកម្មាធិការដើម្បីការពារបេតិកភណ្ឌវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ ដែលជាយន្តការសម្រាប់អនុវត្តអនុសញ្ញា ឆ្នាំ១៩៥៤ ជាមួយនឹងមុខងារចម្បងនៅក្នុងការផ្តល់ ផ្អាក ឬលុបចោលកិច្ចការពារពិសេស និងពិនិត្យសម្រេចផ្តល់ជំនួយអន្តរជាតិ ឬប្រើប្រាស់មូលនិធិដើម្បីការពារបេតិកភណ្ឌវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ។

## សម្តេចប៉ាបអធិដ្ឋានសម្រាប់សហគមន៍ដែលរងគ្រោះដោយគ្រោះធម្មជាតិ

កាលពីថ្ងៃទី ២៧ វិច្ឆិកា ២០១៦ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានអធិដ្ឋានមួយ ជូនដល់ ប្រជាពលរដ្ឋនៅតាមសហគមន៍ នានា ដែលបានកំពុងតែរងគ្រោះនឹងគ្រោះ ធម្មជាតិនានា ដែលបានកើតមានឡើង។

ពិធីអធិដ្ឋាននេះ គឺបានធ្វើឡើងក្រោយ ពេលដែល ប្រជាពលរដ្ឋជាច្រើនកន្លែងនៅ ជុំវិញពិភពលោកបានជួបនឹងគ្រោះធម្មជាតិជាបន្តបន្ទាប់ ជាពិសេស គឺប្រជាពលរដ្ឋនៅក្នុងប្រទេសកូស្តារីការ នីការ៉ាហ្គ័រជា ដើម ។

ប្រទេសទាំងនេះ ត្រូវបានគេដឹងថា បាន ជួបនឹងគ្រោះមហាន្តរាយដ៏ធ្ងន់ធ្ងរបណ្តាល មកពី ព្យុះអូតូ ដែលបានបោកបក់ខ្លាំង សំដៅមកតំបន់អាមេរិកកណ្តាល។

គួររំលឹកដែរថា នៅមុនព្រឹត្តិការណ៍នេះ ប្រទេស នីការ៉ាហ្គ័រ គឺទើបតែទទួលរងនូវ គ្រោះរញ្ជួយដីមួយដ៏ខ្លាំងហើយក៏មកជួប នឹងគ្រោះធម្មជាតិនេះថែមទៀត។

ដោយឡែកនៅក្នុងប្រទេសអ៊ីតាលី ឯណោះវិញ គឺបណ្តាទីក្រុងភាគខាងជើង គឺបានទទួលរង នូវជំនន់ទឹកភ្លៀង ដែល បានជន់លិចសហគមន៍ជាច្រើន។

## សម្តេចប៉ាបជំរុញឲ្យពង្រីកជើងមេឃនៃជំនឿ

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ កាលពីពេល ថ្មីៗនេះ បានប្រកាសបើកការចាប់ផ្តើមនៃ ឆ្នាំនៃជំនឿថ្មី នៅក្នុងកម្មវិធីថ្ងៃអាទិត្យទីមួយ នៃការមកដល់សម្រាប់រដូវនៃបុណ្យព្រះយេស៊ូប្រសូត្រ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានជំរុញឲ្យ គ្រីស្តបរិស័ទ ពង្រឹងជំនឿ ដើម្បីធ្វើយ៉ាង ណា អាចនឹងជួបព្រះជាម្ចាស់ ខណៈដែល ទ្រង់តែងតែចង់ជួបមនុស្សគ្រប់ៗគ្នា។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងទៀត ថា នៅក្នុងអំឡុងពេលនេះ ព្រះយេស៊ូ ទ្រង់ ជំរុញឲ្យយើងទាំងអស់គ្នារិះគិតវាងសកម្មភាពប្រចាំថ្ងៃ និងការយាងមកដល់ដោយ មិនបានព្រាងទុកពីព្រះជាម្ចាស់ ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងទៀត ថា ជាបំណងរបស់ព្រះជាម្ចាស់ គឺមិនមែន ព្រះអង្គកំពុងតែធ្វើឲ្យយើងទាំងអស់គ្នា បារម្ភនោះទេ ប៉ុន្តែព្រះអង្គចង់ឲ្យយើង បើកចំហរជើងមេឃ នៃការរិះគិតរបស់ យើងទាំងអស់គ្នា ដើម្បីឲ្យទ្រង់អាចនឹង បន្តផ្តល់នូវ អត្ថន័យនិងជួយយើងទាំងអស់ គ្នា ឲ្យមានពន្លឺនៅក្នុងការតស៊ូជាមួយនឹង អ្វីៗដែលថ្មី សម្រាប់យើងគ្រប់ៗគ្នា កន្លង មកនិងពេលនេះ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងទៀត ថា សូមបើកចិត្តគំនិត ព្រះជាម្ចាស់ទ្រង់ អាចនឹងយាង មកជួបយើងទាំងអស់គ្នា នៅពេលណាដែលទ្រង់យាងមក ដោយ មិនមែនជាពេលវេលាដែលយើងទាំងអស់ គ្នាបានរំពឹងទុកឡើយ។

## សម្តេចប៉ាបគាំទ្រការរៀបចំឲ្យមានការប្រឡងប្រណាំងយកពានរង្វាន់ រ៉ាហ្សិងជ័ ឆ្នាំ២០១៦

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៦ បានថ្លែងពីការគាំទ្រ របស់ លោកចំពោះការរៀបចំ និងអ្នកដែល ឈ្នះនូវពានរង្វាន់ រ៉ាហ្សិងជ័រ ឆ្នាំ២០១៦ ឡើង។

ការថ្លែងបែបនេះ គឺធ្វើឡើង នៅវិមាន ក្លេមេនទិន ជាកន្លែងដែល រៀបចំការប្រកួត យក ពានរង្វាន់រ៉ាហ្សិងជ័រ ឆ្នាំ២០១៦ ក្រោម ការរៀបចំឡើងដោយ មូលនិធិយ៉ូសែប រ៉ាហ្សិងជ័រ បេណេឌិកទី ១៦ នៃបុរីវ៉ាទីកង់។

ពិធីនេះបានរៀបចំឡើងនៅក្នុងគោល បំណង ផ្តល់នូវសញ្ញានិងតម្លៃចំពោះបណ្ឌិត បញ្ញាជន ទាំងឡាយណាដែលចាប់ អារម្មណ៍នឹង ព្រះសហគមន៍ ហើយធ្វើការ ស្រាវជ្រាវតាមបែប ឬគោលការណ៍បែប វិទ្យាសាស្ត្រនៅក្នុងវិស័យនៃទេវវិទ្យា។

នៅក្នុងពិធីនោះមាន លោកអគ្គអភិបាល អ៊ីណូស ប៉ីហ្វី និងលោក អាយអូនីស កូរ៉ុ ប៉េឡេស ដែលជាសាស្ត្រាចារ្យ និងជា សមាជិកនៃព្រះវិហារ អូតូដុក មួយរូប ផងដែរ ។

វិទ្យុវ៉ាទីកង់ បានអះអាងថា លោក អគ្គអភិបាល ប៉ីហ្វី ដែលមានឈ្មោះ ល្បីល្បាញ នៅក្នុងចំណោមអ្នកទេវវិទ្យា និងអ្នកអប់រំជំនឿ ក៏ទទួលបានពាន រង្វាន់កិត្តិយស នេះផងដែរ ។

## លោកស្រី អ៊ុងសានស៊ូជី ត្រូវក្រុមអ្នកតវ៉ាអំពាវនាវឱ្យដកហូតរង្វាន់ណូបែលសន្តិភាព

ក្រុមអ្នកចូលរួមការតវ៉ាមួយដែលត្រូវ បានធ្វើកាលពីពេលថ្មីៗនេះបានស្រែក ទាមទារឲ្យ ដកពានរង្វាន់ណូបែលសន្តិ-ភាពពីលោកស្រី អ៊ុង សានស៊ុជី ខណៈ ដែលប្រទេសភូមាក្រោមការដឹកនាំដោយ គណបក្សរបស់លោកស្រីបរាជ័យនៅក្នុង ការដោះស្រាយបញ្ហាហិង្សាប្រឆាំងនឹងជន មូស្លីមនៅក្នុងប្រទេសភូមា។

តាមសេចក្តីរាយការណ៍ព័ត៌មានបរទេស បានឲ្យដឹងថានេះគឺជាការតវ៉ា ដែលគេបាន រៀបចំឡើង នៅក្នុងប្រទេសឥណ្ឌូនេស៊ីដើម្បី ប្រឆាំងការគាបសង្កត់និងការសម្លាប់ក្រុម ជនជាតិភាគតិចអ៊ីស្លាមរ៉ូហ៊ីងយ៉ានោះ។

លោកស្រី អ៊ុន សាន ស៊ូជី បានទទួល ពានរង្វាន់ណូបែលសន្តិភាពនេះ កាលពី ឆ្នាំ១៩៩១ ប៉ុន្តែក្រុមនិស្សិតរាប់សិបនាក់ ដែលមកពីសកលវិទ្យាល័យអ៊ីស្លាម Ibnu Chaldunនៅប្រទេសឥណ្ឌូនេស៊ី បានទាម ទារឱ្យគ្រប់ភាគីទាំងអស់បញ្ឈប់ការសម្លាប់ ជនជាតិរ៉ូហ៊ីងយ៉ា។

លោកជុលគីហ្វលី អែល អាល់លី អ្នក សម្របសម្រួលការរៀបចំការតវ៉ានេះ បាន និយាយនៅអំឡុងពេលប្រមូលផ្តុំតវ៉ានៅមុខ ស្ថានទូតមីយ៉ាន់ម៉ានៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ីថា "យើងទាមទារឱ្យ មានការដកហូតពានរង្វាន់ណូបែលសន្តិ-ភាពដែលត្រូវបានផ្តល់ឱ្យលោកស្រីអ៊ុង សានស៊ូជី"។

ការតវ៉ានេះបានទាមទាររដ្ឋាភិបាល ឥណ្ឌូនេស៊ី បង្កើនឲ្យខំប្រឹងប្រែងដើម្បី បញ្ឈប់ការវាយប្រហាររបស់ក្រុមអាជ្ញាធរ មីយ៉ាន់ម៉ាទៅលើក្រុមជនជាតិរ៉ូហ៊ីងយ៉ា។

## សម្តេចប៉ាប៖ ប្រាក់កាសត្រូវតែបម្រើប្រយោជន៍មនុស្ស មិនមែនជាអភិបាលកិច្ច

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានមាន ព្រះបន្ទូលប្រាប់សហគ្រិន ៥០០នាក់ មកពីជុំវិញពិភពលោកថា "មានទ្រព្យ សម្បត្តិគឺល្អ នៅពេលវាបម្រើដល់មនុស្ស ជាតិ"។ លោកបន្តថា ប្រាក់កាសត្រូវតែ បម្រើប្រយោជន៍មនុស្ស មិនមែនគ្រប់គ្រង មនុស្សនោះទេ។ សម្តេចប៉ាបបញ្ជាក់ "សកម្មភាពមនុស្សទាំងអស់ រួមមានមុខ ជំនួញ អាចជាប្រតិបត្តិការនៅក្នុងធម៌មេត្តា ករុណាដែលមានន័យថា ចូលរួមចែករំលែក សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះ មនុស្សជាតិ"។

សម្តេចប៉ាបបានមានបន្ទូលបញ្ជាក់យ៉ាង ជាក់លាក់អំពីទំនួលខុសត្រូវ និងបញ្ហា ប្រឈមនៃមុខជំនួញ។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ មានព្រះបន្ទូលថា "ខ្ញុំសូមរិះគិត ជាមួយអ្នករាល់គ្នាអំពីហានិភ័យបីប្រការ ពាក់ព័ន្ធនៅក្នុងសកម្មភាពជំនួញគឺ ការ ប្រើប្រាស់ប្រាក់កាសដោយសមរម្យ ភាព ស្មោះត្រង់ និងភាតរភាព។

សម្តេចប៉ាបបានផ្តល់នូវយោបល់ថា "ឥណទានគួរតែផ្តល់ជូនដល់ជំនួញគ្រួសារ សហគ្រាសខ្នាតតូច កសិករ គម្រោងដែល អភិវឌ្ឍសហគមន៍ជាដើម"។ សម្តេចប៉ាប ស្នើសុំពួកគេ គិតគូរឲ្យបានល្អិតល្អន់អំពី ភាពស្មោះត្រង់ ពីព្រោះតែ "អំពើពុករលួយ ជាទុក្ខទោសអាក្រក់បំផុតនៃសង្គម"។

ព្រះអង្គក៏បានស្នើសុំពួកគេថា ទំនាក់-ទំនងរវាងនិយោជក និងនិយោជិតមិន ត្រូវបានកំណត់ជាយុត្តិធម៌នោះទេ ពី ព្រោះតែ "ជំនួញជាសហគមន៍នៃការងារ ដែលត្រូវទទួលបានសេចក្តីគោរព និងការ លើកទឹកចិត្តជាបងប្អូនពីអ្នកគ្រប់គ្រង សហការី និងមនុស្សក្រោមបង្គាប់របស់ ពួកគេ"។ សម្តេចប៉ាបមានព្រះបន្ទូល ប្រាប់អ្នកជំនួញទាំងនោះថា ពួកគេក៏ អាចជាសន្តបុគ្គលបានដែរ។

ព្រះអង្គបានលើកឡើងអំពីគំរូរបស់ លោក អេនរី( Enrique Shaw) ជាអ្នក ជំនួញម្នាក់ ដែលជំរុញអោយជំនួញរីក ចម្រើន តាមគោលលិទ្ធិសង្គមនិងតាម ជំនឿកាតូលិក។



បូជាចារ្យ សែ សាត

## អាទិត្យទី២ រដូវរង់ចាំ ប្រចាំឆ្នាំ ក អត្ថបទ មថ ៣,១-១២

យើងម្នាក់ៗមានឋានៈដូចលោកយ៉ូហានបាទីស្ដដែរ គឺទី១ រៀបចំរបៀបរស់នៅរបស់យើងឲ្យបានត្រឹមត្រូវ ដើម្បីទទួលព្រះយេស៊ូដែលកំពុងយាងមក។ "ចូរប្រែចិត្តគំនិតឡើង ដ្បិតព្រះរាជ្យនៃស្ថានបរមសុខ មកជិតបង្កើយហើយ!"។..."ចូររៀបចំផ្លូវរបស់ព្រះអម្ចាស់ ចូរតម្រង់ផ្លូវថ្វាយព្រះអង្គ!"។ តើជីវិតរស់នៅរបស់យើងមានចិត្តច្រណែន លោភលន់ ខ្ជិលច្រអូស ស្រើបស្រាល ខឹងចងគំនុំ ផឹកស៊ីហួសប្រមាណ កេងប្រវ័ញ្ច និយាយកុហកឬនិយាយដើមគេ...ឬទេ? តើយើងបានស្រលាញ់ព្រះជាម្ចាស់គ្រប់គ្រាន់ និងស្រលាញ់បងប្អូនឯទៀតៗដូច ស្រលាញ់ខ្លួនឯងឬទេ? តើម្នាក់ៗត្រូវកែចំណុចអ្វីខ្លះក្នុងជីវិតរបស់ខ្លួន? ចូរប្រព្រឹត្តអំពើល្អដើម្បីបញ្ជាក់ថាអ្នករាល់គ្នាបានប្រែចិត្តគំនិតមែន។ ទី២ប្រកាសអំពីឋានៈរបស់ព្រះអង្គក្នុងជីវិតរបស់យើងដល់មនុស្សឯទៀតៗឲ្យគេស្គាល់។ លោកយ៉ូហានប្រកាសអំពីឋានៈដ៏ខ្ពង់ខ្ពស់របស់ព្រះយេស៊ូ គឺថាលោកយ៉ូហានធ្វើពិធីជ្រមុជទឹកដើម្បីឲ្យមនុស្សកែប្រែចិត្តគំនិត ហើយត្រឡប់មករកព្រះជាម្ចាស់វិញ ដោយពោលថា៖ ខ្ញុំធ្វើពិធីជ្រមុជអ្នករាល់គ្នាក្នុងទឹក ដើម្បីឲ្យអ្នករាល់គ្នាបានប្រែចិត្តគំនិត ប៉ុន្ដែលោកដែលមកក្រោយខ្ញុំលោកមានកម្លាំងខ្លាំងជាងខ្ញុំ។ ខ្ញុំមានឋានៈទាបណាស់សូម្បីតែដោះស្បែកជើងជូនលោក ក៏មិនសមនឹងឋានៈដ៏ខ្ពង់ខ្ពស់របស់លោកផង។ លោកនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងដោយភ្លើងវិញ។ លោកកាន់ចង្អេរ លោកសម្អាតលានបោកស្រូវ អុំស្រូវយកគ្រាប់ល្អរបស់លោកប្រមូលដាក់ជង្រុក រីឯសំដីវិញ លោកនឹងដុតក្នុងភ្លើងដែលឆេះពុំចេះរលត់ឡើយ។ ជាការពិតណាស់អគ្គសញ្ញាជ្រមុជទឹកដែលយើងទទួល គឺជាត្រាបញ្ជាក់ជំនឿរបស់យើងលើព្រះយេស៊ូ (លោកTertullian)។ ព្រះអង្គធ្វើពិធីជ្រមុជទឹកឲ្យយើងក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយភ្លើងនៃព្រះវិញ្ញាណដ៏វិសុទ្ធនោះដុតជំរះយើងពីបាបដើម។ ព្រះអង្គនឹងជំរះយើងឲ្យបានស្អាតបរិសុទ្ធ និងទៅជាជនដ៏វិសុទ្ធដូចព្រះអង្គជាព្រះដ៏វិសុទ្ធ ដើម្បីយើងអាចរួមរស់ជាមួយព្រះបិតានៅស្ថានបរមសុខបាន។ ដោយសារអគ្គសញ្ញានេះ យើងទៅជាព្យាការី មហាក្សត្រ និងបូជាចារ្យ ហើយត្រូវរស់នៅតាមអគ្គសញ្ញាណនេះជាប្រចាំថ្ងៃដែរ។

## អាទិត្យទី ៣ រដូវរង់ចាំ ប្រចាំឆ្នាំ ក អត្ថបទ មថ ១១,២-១១

ពេលនោះ លោកយ៉ូហានជាប់ក្នុងមន្ទីរឃុំឃាំងហើយឮគេនិយាយអំពីកិច្ចការទាំងប៉ុន្មាន ដែលព្រះគ្រីស្ដបានធ្វើ។ លោកក៏ចាត់សិស្សឲ្យទៅទូលសួរព្រះយេស៊ូថា៖ "តើលោកជាព្រះគ្រីស្ដដែលត្រូវយាងមក ឬមួយយើងខ្ញុំត្រូវរង់ចាំម្នាក់ផ្សេងទៀត?"។ ព្រះយេស៊ូមានព្រះបន្ទូល ទៅសិស្សទាំងនោះថា៖ "ចូរអ្នករាល់គ្នាទៅជម្រាបលោកយ៉ូហាននូវហេតុការណ៍ ដែលអ្នករាល់គ្នាបានឮ និងបានឃើញនេះទៅ គឺមនុស្សខ្វាក់មើលឃើញ មនុស្សខ្វិនដើរបាន មនុស្សឃ្លង់ជាស្អាតបរិសុទ្ធ មនុស្សថ្លង់ស្ដាប់ឮ មនុស្សស្លាប់បានរស់ឡើងវិញ ហើយមានគេនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ អ្នកណាមិនរវាតចិត្តចេញពីជំនឿដោយសារខ្ញុំ អ្នកនោះពិតជាមានសុភមង្គលហើយ!"។ យើងដូចលោកយ៉ូហានបាទីស្ដដែរ គឺលោកត្រូវរង់ចាំ ព្រះយេស៊ូគ្រីស្ដដែលកំពុងយាងមក។ យើងទទួលស្គាល់ថា ព្រះយេស៊ូបាននាំព្រះរាជ្យរបស់ព្រះជាម្ចាស់មកដល់ផែនដីនេះហើយ។ ព្រះយេស៊ូជាព្រះគ្រីស្ដ និងជាព្រះសង្គ្រោះដែលកំពុងយាងមក។ ព្រះអង្គកំពុងយាងមក គឺព្រះអង្គមានវត្តមានរួចហើយ នៅក្នុងព្រះកាយរបស់ព្រះអង្គ គឺព្រះសហគមន៍។ ហេតុនេះ ចូរយើងបើកដួងចិត្តទទួលព្រះអង្គក្នុងជីវិតយើង ដើម្បីឲ្យយើងមានបទពិសោធន៍អំណរសប្បាយដោយទទួលការសង្គ្រោះពីព្រះអង្គ នោះយើងពិតជាមានសុភមង្គលមិនខាន។ លើសពីនេះ ឲ្យម្នាក់ៗដឹងថា ពីមួយថ្ងៃទៅមួយថ្ងៃ ខ្លួនឯងត្រូវក្លាយទៅជាព្រះគ្រីស្ដមួយអង្គទៀត ហើយបន្តកិច្ចការរបស់ព្រះអង្គ ដើម្បីឲ្យមនុស្សឯទៀតៗទទួលអំណរសប្បាយ និងការសង្គ្រោះពីព្រះអង្គដូចម្នាក់ៗបានទទួលដែរ។

## អាទិត្យទី ៤ រដូវរង់ចាំ ប្រចាំឆ្នាំ ក អត្ថបទ មថ ១,១៨-២៤

ព្រះជាម្ចាស់ប្រសូតជាមនុស្ស ហើយគង់នៅក្នុងចំណោមមនុស្សទាំងអស់។ នៅពេលដែលលោកយ៉ូសែបទទួលដំណឹងថា នាងម៉ារីមានផ្ទៃពោះដោយមិនទាន់ រៀបការជាមួយលោក លោកចង់ផ្ដាច់ពាក្យស្ងាត់ៗ។ ទេវទូតរបស់ព្រះអម្ចាស់មកប្រាប់លោកក្នុងសុបិន្តថា៖ "លោកយ៉ូសែបជាព្រះរាជវង្ស របស់ព្រះបាទដាវីឌអើយ សូមកុំខ្លាចនឹង ទទួលនាងម៉ារី មកធ្វើជាភរិយាឡើយ! បុត្រដែលនៅក្នុងផ្ទៃនាងកើតមកពីព្រះវិញ្ញាណដ៏វិសុទ្ធ។ នាងនឹងសម្រាលបានបុត្រមួយ ហើយលោកត្រូវថ្វាយព្រះនាមថា "យេស៊ូ" ដ្បិតបុត្រនោះនឹងសង្គ្រោះប្រជារាស្ដ្រព្រះអង្គឲ្យរួចពីបាបរបស់គេ"។ តើយើងជឿព្រះបន្ទូលនេះទេ? ដូចក្នុងធម៌ជឿរបស់ព្រះសហគមន៍ទាំងមូល យើងបានប្រកាសថា៖ ខ្ញុំជឿព្រះយេស៊ូគ្រីស្ដជាព្រះបុត្រាតែមួយនៃព្រះបិតា ហើយជាអម្ចាស់យើងខ្ញុំ។ ព្រះអង្គបានចាប់កំណើតជាមនុស្ស ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ហើយទ្រង់បានប្រសូតពីព្រះនាងព្រហ្មចារិនីម៉ារី...។ នៅពេលដែលព្រះយេស៊ូចាកចេញពីសាវ័កយាងឡើងស្ថានបរមសុខ ព្រះអង្គមានព្រះបន្ទូលចុងក្រោយថា៖ ចូរដឹងថាខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក (មថ ២៨,២០)។ ព្រះអម្ចាស់មានព្រះបន្ទូលតាមរយៈព្យាការីថា៖ (មើល!ស្ដ្រីព្រហ្មចារីនឹងមានផ្ទៃពោះនាងនឹងសម្រាលបានបុត្រមួយ ដែលគេនឹងថ្វាយព្រះនាមថា "អេម៉ានូអែល") ប្រែថា "ព្រះជាម្ចាស់គង់ជាមួយយើង"។ ព្រះយេស៊ូគ្រីស្ដដែលនឹងប្រសូត ព្រះអង្គដែលមានព្រះជន្មរស់ឡើងវិញ គង់នៅជាមួយ យើងម្នាក់ៗ។ ព្រះអង្គមានវត្តមាននៅក្នុងពិភពលោកនេះ តាមរយៈព្រះកាយរបស់ព្រះអង្គដែលជាព្រះសហគមន៍។ យើងមើលព្រះអង្គឃើញតាមរយៈកិច្ចការរបស់យើង ដោយប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គ។ ព្រះអង្គមានវត្តមាននៅក្នុងអភិបូជាដែលយើងកំពុងចូលរួម។ ដូច្នេះហើយ ចូរយើងម្នាក់ៗយកគំរូតាមព្រះនាងម៉ារី គឺដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យព្រះអង្គប្រសូតចេញពីជីវិតរបស់យើងម្នាក់ៗមកក្នុងពិភពលោកសព្វថ្ងៃនេះផង។

## អាទិត្យ បុណ្យព្រះយេស៊ូប្រសូត ប្រចាំឆ្នាំក (ពេលយប់ )៖ អត្ថបទ លក ២, ១-១៤

យើងដែលជាមនុស្សទាន់ទាប ចូរកុំអស់សង្ឃឹមឡើយ ពីព្រោះព្រះជាម្ចាស់បានជូនកាដូពិសេសបំផុតសំរាប់ម្នាក់ៗ គឺព្រះអង្គប្រទានព្រះបុត្រាតែមួយព្រះអង្គគត់ឲ្យយើង។ ព្រះអង្គស្រលាញ់យើងដល់ទីបំផុត គឺព្រះជាម្ចាស់ បានសម្ដែងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ ក្នុងចំណោមយើង គឺព្រះអង្គបានចាត់ព្រះបុត្រាតែមួយគត់របស់ព្រះអង្គ ឲ្យយាងមកក្នុងលោកនេះ ដើម្បីឲ្យយើងមានជីវិតដោយសារព្រះបុត្រា (៣ យហ ៤,៩)។ ហេតុនេះ យើងមិនត្រូវភ័យខ្លាចអ្វីឡើយ ចូរយើងទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ថ្លែងតាមរយៈទេវទូតរបស់ព្រះអង្គដល់គង្វាលថា៖ "កុំខ្លាចអ្វីឡើយ ខ្ញុំនាំដំណឹងល្អមួយមកប្រាប់អ្នករាល់គ្នា។ ដំណឹងនេះនឹងធ្វើឲ្យប្រជារាស្ដ្រទាំងមូល មានអំណរដ៏លើសលប់។ យប់នេះនៅក្នុងភូមិកំណើតរបស់ព្រះបាទដាវីឌ ព្រះសង្គ្រោះរបស់អ្នករាល់គ្នាប្រសូតហើយ គឺព្រះគ្រីស្ដជាអម្ចាស់។ នេះជាសញ្ញាសម្គាល់ឲ្យអ្នករាល់គ្នាដឹង គឺអ្នករាល់គ្នាមុខជាឃើញទារកមួយទើបនឹងប្រសូត រុំដោយសំពត់ ផ្ដេកនៅក្នុងស្នូកសត្វ"។ ចូរយើងត្រៀមខ្លួនទៅថ្វាយ បង្គំព្រះកុមារយេស៊ូ ដោយផ្ញើជីវិត ទាំងស្រុងលើព្រះអង្គ ពីព្រោះព្រះអង្គជាព្រះសង្គ្រោះរបស់យើង និងផ្ដល់សុភមង្គលពិតប្រាកដដល់យើង។ ជាមួយគ្នានោះដែរ ចូរយើងអរព្រះគុណព្រះជាម្ចាស់ និងកោតសរសើរលើកតម្កើងព្រះអង្គរួមជាមួយទេវទូតរបស់ព្រះអង្គថា៖ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅស្ថានដ៏ខ្ពស់បំផុត ហើយសូមឲ្យមនុស្សលោកដ៏ជាទីស្រលាញ់របស់ព្រះអង្គ បានប្រកបដោយសេចក្ដីសុខសាន្តនៅលើផែនដី។



# វិទ្យាស្ថានសន្តប៉ូល

អាសយដ្ឋាន៖ ភូមិអង្គគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ

Tel: 032 639 0002/ 032 639 0003 | E: spi.takeo@gmail.com | W : www.spi.edu.kh

## ថ្នាក់បរិញ្ញាបត្រ

**មហាវិទ្យាល័យព័ត៌មានវិទ្យា**
**Faculty of Information Technology**

- វិស្វកម្មកម្មវិធី Software Engineering
- ទូរគមនាគមន៍ និងបណ្តាញ Telecommunication and Network

**ដេប៉ាតឺម៉ង់អក្សរសាស្ត្រអង់គ្លេស**
**Department of English Literature**

- អប់រំភាសាអង់គ្លេស Teaching English as Foreign Language
- ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង English for Communication

**ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍**
**Department of Tourism Management**

- គ្រប់គ្រងទេសចរណ៍ Tourism Management

**ដេប៉ាតឺម៉ង់កសិកម្មសាស្ត្រ**
**Department of Agronomy**

- កសិកម្មសាស្ត្រ Agronomy

**ដេប៉ាតឺម៉ង់សង្គមកិច្ច**
**Department of Social Work**

- សង្គមកិច្ច Social Work

## ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

- **អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ** Software Development
- **គ្រប់គ្រងប្រព័ន្ធ និងបណ្តាញកុំព្យូទ័រ** System and Network Administration
- **បង្រៀនភាសាអង់គ្លេស** English Language
- **សណ្ឋាគារ និងបដិសណ្ឋារកិច្ច** Hotel and Hospitality
- **ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ** Fruit and Vegetable Crop Production
- **ជំនាញកែច្នៃអាហារ** Food Processing
- **ប្រព័ន្ធកសិកម្មចម្រុះ** Integrated Farming System

## លក្ខខណ្ឌចូលរៀន

១. បេក្ខជនត្រូវមានសញ្ញាបត្រទុតិយភូមិ (ជាប់ថ្នាក់ទី១២) ឬសញ្ញាបត្រដែលមានតម្លៃស្មើ សម្រាប់ចូលរៀនថ្នាក់បរិញ្ញាបត្រ

២ បេក្ខជនធ្លាក់ថ្នាក់ទី១២អាចចូលរៀន ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស



**ចាប់ផ្តើមលក់ពាក្យ និងទទួលពាក្យ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ**

- ចូលរៀនវគ្គបំប៉ន ខែកញ្ញា ឆ្នាំ២០១៦
- ចូលរៀនឆមាសទី១ ខែវិច្ឆិកា ឆ្នាំ២០១៦